

# ព្រឹត្តិបត្រប្រចាំខែ

Monthly Newsletter

# ការអប់រំ និង បច្ចេកវិទ្យា

# Education & Technology





Android iOS

Android iOS



ឆ្នាំទី៣ លេខ០០៧ ចេញផ្សាយប្រចាំខែឧសភា-ធ្នូ ២០២៣

ការិយាល័យ: សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម។
ប្រអប់សំបុត្រ: P.O Box ១៦២១ ភ្នំពេញ កម្ពុជា 042 941 481/042 941 918។

kape@kapekh.org www.kapekh.org www.facebook.com/kapeaction www.twitter.com/KAPECambodia

www.youtube.com/TheKapeCambodia www.linkedin.com/in/kapecambodia/

# មាតិកា

ទំព័រ


១ អំពីអង្គការ ខេប, ចំនួនគម្រោងកំពុងប្រតិបត្តិ, អ្នកទទួលផល
២ ម្ចាស់ជំនួយក្នុងឆ្នាំ២០២២

**១. ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ (NGS)**
៤ សេវាប្រឹក្សាជាអាជីពជាអ្វីនៅក្នុងវិស័យអប់រំ?
៤ គណកម្មការវាយតម្លៃទទួលស្គាល់គុណភាពអប់រំសាលារៀនជំនាន់ថ្មី
៥ កសាងមូលធនមនុស្សចាំបាច់ត្រូវការសិស្សមានគុណភាព

**២. បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការអប់រំ**
៨ ការចុះចួបសិស្សានុសិស្សក្នុងការធ្វើតេស្តEGRA
៨ ជំរុញការប្រើប្រាស់ICTក្នុងវិស័យអប់រំដល់សាលារៀនគោលដៅ
៩ តើអ្វីទៅជា WeThinkDigital ?
១០ បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សា

**៣. ការអភិវឌ្ឍគ្រូបង្រៀន**
១២ ទស្សនៈកិច្ចសិក្សាគ្រូកិច្ចសន្យាផ្ទើមប្រចាំគម្រោងជំនាន់ទី១
១២ ការគ្រប់គ្រងថ្នាក់រៀន ពិតជាសំខាន់សម្រាប់ទាក់ទាញសិស្ស
១៣ ការអភិវឌ្ឍភាពជាអ្នកដឹកនាំដល់ជាមន្ត្រីក្រសួងអប់រំ
១៤ ការសិក្សាផ្នែកទំនាក់ទំនងជាលក្ខណៈវេទិកា
១៥ ពង្រឹងសមត្ថភាពលើការប្រើប្រាស់កម្មវិធីគ្រូមត្តេយ្យ

**៤. កម្មវិធីអប់រំបរិយាប័ន្ន**
១៧ ឱកាសផ្លាស់ប្តូរជីវិតកុមារពិការកាយ តែមិនពិការគំនិត
១៩ កុមារីងាយរងគ្រោះបានប្តូរពន្លឺមាគ៌ាជីវិតថ្មី
២១ ហេតុអ្វីយុវជនត្រូវយល់ដឹងពីយុគសម័យឌីជីថល?
២៣ កម្មវិធីត្រីវិស័យជួយគ្រូបង្រៀន និងដឹកនាំសិស្សបង្កើតទិសដៅជីវិត
២៥ ថវិកាបដិភាគពន្លឿនដំណើរការអភិវឌ្ឍន៍សាលារៀន

**៥. កម្មវិធីអំណានថ្នាក់ដំបូង**
២៨ ថវិកាបដិភាគពន្លឿនដំណើរការអភិវឌ្ឍន៍សាលារៀន

**៦. កម្មវិធីមត្តេយ្យសិក្សា**
៣១ តើកុមាត្រូវការអាហារូបត្ថម្ភអ្វីខ្លះសម្រាប់ការលូតលាស់?

**៧. រចនាបថហេដ្ឋារចនាសម្ព័ន្ធ**
៣៣ ហេតុអ្វីបានជាហេដ្ឋារចនាសម្ព័ន្ធសាលាគោលដៅអភិវឌ្ឍន៍លឿន ?

**៨. ការអភិវឌ្ឍបណ្ណាល័យ**
៣៥ បណ្ណាល័យនៅតែដើរតួនាទីសំខាន់សម្រាប់សិស្សនាពេលបច្ចុប្បន្ន

**៩. កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព**
៣៧ ប្រជុំឆ្លុះបញ្ចាំងពីការអនុវត្តកម្មវិធីបំណិនជីវិតតាមសាលាគោលដៅ

**១០. កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩**
៣៩ ការប្រើប្រាស់កញ្ចប់សិក្សាបំប៉នបន្ថែមដល់សិស្សដែលរៀនយឺត

**១១. ព្រឹត្តិការណ៍ ការស្រាវជ្រាវចំណេះដឹង និងការកំសាន្តផ្សេងៗ**
៤១ អង្គការ ខេប បានចុះកិច្ចសន្យាជាមួយលោក ដែន ឧល់ណាសិន
៤១ បិទបញ្ចប់គម្រោង និងពិភាក្សាអំពីផែនការនិរន្តរភាព
៤៣ ការទទួលប្រាក់សំណងពីក្រុមហ៊ុនរ៉ាប់រងអាយុជីវិត ហ្វតតេ

៤៣ លោក ឯម កុសល បានផ្តល់អង្ករ និងអាវយឺតដល់សិស្សងាយរងគ្រោះ
៤៤ ពិនិត្យ និងកែសម្រួលគោលនយោបាយ GEDSI របស់អង្គការខេប
៤៤ ដំណើរទស្សនកិច្ចសិក្សាម្ចាស់ជំនួយនៅតាមសាលារៀនគោលដៅ
៤៥ ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ
៤៥ ការដាក់ឱ្យដំណើរការជាផ្លូវការនៃកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ
៤៦ ការឆ្លុះបញ្ចាំងកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន
៤៨ អង្គវិបស្សនាបុគ្គលិកប្រចាំឆ្នាំអង្គការ ខេប



## ព្រឹត្តិបត្រ "ការអប់រំ និងបច្ចេកវិទ្យា"
## រៀបចំផលិត និងចេញផ្សាយដោយ

| | | |
|---|---|---|
| លោក អឿ សាវីន | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ | រៀបចំផែនការ បង្កើតទម្រង់ និងរចនា |
| លោក ឈួន តារា | មន្ត្រីបច្ចេកវិទ្យាព័ត៌មានជាន់ខ្ពស់ | ជំនួយការបច្ចេកទេស |
| លោក វ៉ាន់ សុខសារៈ | មន្ត្រីតាមដាន & វាយតម្លៃ និងគ្រប់គ្រងទិន្នន័យជាន់ខ្ពស់ | ជំនួយការផ្នែកទិន្នន័យ |
| លោក ម៉ៃ សុខឃា | មន្ត្រីព័ត៌មានវិទ្យា | ជំនួយការបច្ចេកទេស |
| កញ្ញា ជ្រន ភាត់ថា | ជំនួយការផ្នែកទំនាក់ទំនង | ប្រមូល និងសរសេរព័ត៌មាន |

## ត្រួតពិនិត្យ និងកែសម្រួលខ្លឹមសារដោយ

**លោក ស សុផាណាក់**
ប្រធានសម្របសម្រួលផ្នែកបច្ចេកវិទ្យាសម្រាប់ការអប់រំ

# អំពីអង្គការ ខេប

ខេប គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១៥០០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ដែលបង្រៀននៅជាង ៤០០សាលាក្នុង១៣រាជធានី-ខេត្ត។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនងាយរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី ឬច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

**ការអភិវឌ្ឍមនុស្ស ប្រកបដោយសេចក្តីថ្លៃថ្នូរ!**

## លំដាប់គម្រោងតាមផ្នែកបច្ចេកទេសរបស់អង្គការ ខេប ក្នុងឆ្នាំ២០២៣

| គម្រោងរបស់អង្គការ ខេប ក្នុងឆ្នាំ២០២៣ | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀនធម្មនុញ | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាបន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមត្តេយ្យសិក្សា | រចនាបថហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍបណ្ណាល័យ | កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព |
|---|---|---|---|---|---|---|---|---|---|---|
| ១. កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន | ADLP | | ✓ | | | | | | | |
| ២. គម្រោង សៀវភៅសម្រាប់កម្ពុជា | BfC | | | | | | | | ✓ | |
| ៣. គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម | COSAVED | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ៤. គម្រោង ងាយស្រួលរៀន – ខេត្តព្រៃវែង | E2L-PV | | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៥. គម្រោង ងាយស្រួលរៀន – ខេត្តក្រចេះ | E2L-Kr | | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៦. គម្រោង ពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា | EQUAL | | | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៧. កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុ | FLP | | | ✓ | | | | | | ✓ |
| ៨. គម្រោង សហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិច តំបន់១ | FOSTER | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ៩. គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ១០. កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ | KDLP | | ✓ | ✓ | | | | | | ✓ |
| ១១. កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន | LLSP | | | ✓ | | | | | | ✓ |
| ១២. គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ |
| ១៣. គម្រោងអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន | MDL | | ✓ | ✓ | | | | | | ✓ |
| ១៤. កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈភាពជាអ្នកដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា | MLPDP | | ✓ | | ✓ | | | | | |
| ១៥. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | | | | | | |
| ១៦. កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតបឋមសិក្សា) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៧. កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតមធ្យមសិក្សា) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ |
| ១៨. បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACHIV | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ២៩. គម្រោង វាយតម្លៃការសិក្សាថ្នាក់ដំបូង | EGLA | | | | | ✓ | | | | |
| ២០. គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ |
| សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ | | 3 | 10 | 15 | 11 | 9 | 4 | 4 | 11 | 15 |

# ចំនួនអ្នកទទួលផលផ្ទាល់







**១២០៨៣១** សិស្សានុសិស្ស

**២៨០៦** គ្រូបង្រៀន/នាយក

**១៤៩៦** ភាគីពាក់ព័ន្ធ

# ចំនួនសាលាគោលដៅ





**១១០** មធ្យមសិក្សា

**១៧២** បឋមសិក្សា





**៤២** មត្តេយ្យសិក្សា

**១** ឧត្តមសិក្សា

# ម្ចាស់ជំនួយអង្គការ ខេប ក្នុងឆ្នាំ២០២១

unicef for every child
GPE Transforming Education
GVC WeWorld
This project is co-funded by the European Union
EDUCATE A CHILD — A programme of education above all
Aide et Action — Changing the world through Education
THE PHOENIX FOUNDATION
ChildFund Cambodia
ADB
The Asia Foundation — Improving Lives, Expanding Opportunities
OXFAM
lotus outreach INTERNATIONAL
lotus outreach SOCIETY CANADA
USAID FROM THE AMERICAN PEOPLE
pact building local promise.
Oaktree
UNESCO
FFF | Franks Family Foundation
Gap Inc.
P.A.C.E. Gap Inc. Advancing Women to Advance the World

# តំបន់គោលដៅអនុវត្តគម្រោងក្នុងឆ្នាំ២០២១ របស់អង្គការ ខេប មានចំនួន ១៣ រាជធានី-ខេត្ត



អនុវិស័យទី ១

# ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ

*"បង្កើតសាលារៀនរដ្ឋជាមួយនឹងស្តង់ដាសាលារៀនឯកជន"*

# Charter School Development

*Creating Public Schools with Private School Standards*









# សេវាប្រឹក្សាជាអាជីពជាអ្វីនៅក្នុងវិស័យអប់រំ ?



វគ្គតម្រង់ទិសអំពីសេវាប្រឹក្សាអាជីពដល់គ្រូប្រឹក្សាអាជីពថ្មីក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី។

ការផ្តល់សេវាប្រឹក្សាអាជីព និងព័ត៌មានស្តីពីការសិក្សាជំនាញ គឺជួយសិស្សបង្កើនចំណេះដឹងខ្លួនឯង ស្វែងយល់ពីបុគ្គលិកលក្ខណៈ អារម្មណ៍ ចំណង់ចំណូលចិត្ត និងការចាប់អារម្មណ៍ ជាពិសេសលើកទឹកចិត្តសិស្សក្នុងការបង្ហាញបំណងប្រាថ្នា និងក្តីសុបិន្តសម្រាប់អនាគតរបស់ពួកគេ។ ដើម្បីឱ្យការផ្តល់ការប្រឹក្សាអាជីពកាន់តែល្អប្រសើរ កម្មវិធីសាលារៀនជំនាន់ថ្មី បានរៀបចំវគ្គតម្រង់ទិសអំពីសេវាប្រឹក្សាអាជីពដល់គ្រូប្រឹក្សាអាជីពថ្មីចំនួនប្រាំមួយនាក់ ដែលមកពីសាលារៀនជំនាន់ថ្មីចំនួនបួន រួមមាន៖ វិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យព្រែកលៀប វិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ និងវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដែលធ្វើឡើងនៅបន្ទប់ប្រឹក្សាអាជីពនៃវិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ។

វគ្គតម្រង់ទិសនេះ ប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ដែលមានគោលបំណងណែនាំអំពីសេវាប្រឹក្សាអាជីពទៅដល់គ្រូថ្មីដែលទើបចូលមកបំពេញកិច្ចការងារជាគ្រូប្រឹក្សាអាជីពក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី និងស្វែងយល់អំពីសកម្មភាពសេវាប្រឹក្សាអាជីព ផែនការសកម្មភាព និង ការចំណាយថវិកា។

ក្នុងវគ្គតម្រង់ទិសនេះ មានប្រាំផ្នែកធំៗដែលគ្រូប្រឹក្សាអាជីពត្រូវយល់ដឹង រួមមាន ៖ ការផ្តល់សេវាប្រឹក្សាអាជីព គ្រូទីប្រឹក្សាអាជីព តួនាទីភារកិច្ចគ្រូទីប្រឹក្សាអាជីពនិងអ្នកពាក់ព័ន្ធ ដំណើរការអនុវត្តសកម្មភាពសេវាប្រឹក្សាអាជីព និងការពិនិត្យតាមដាន និងវាយតម្លៃ។

ដូច្នេះសេវាប្រឹក្សាអាជីព ពិតជាផ្នែកមួយជួយឱ្យសិស្សស្វែងយល់ពីចំណុចខ្លាំង ចំណុចខ្សោយ ជំនាញ បុគ្គលិកលក្ខណៈល្អៗ និងរកឱ្យឃើញនូវរបៀបនៃការអភិវឌ្ឍចំណុចខ្សោយ តាមរយៈការសិក្សា និងការអនុវត្ត ជាពិសេសលើកទឹកចិត្តឱ្យពួកគេយកចិត្តទុកដាក់ចំពោះជំនាញគ្រប់គ្រងជីវិតដែលអាចគាំទ្រដល់ការសិក្សា៕

# គណកម្មការវាយតម្លៃទទួលស្គាល់គុណភាពអប់រំសាលារៀនជំនាន់ថ្មី



សកម្មភាពក្រុមប្រឹក្សាភិបាលវាយតម្លៃទទួលគុណភាពអប់រំនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម។

ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣នេះ អនុគណៈកម្មការវាយតម្លៃទទួលស្គាល់គុណភាពអប់រំសាលារៀនជំនាន់ថ្មី (NGS Accreditation Committee) បានចុះវាយតម្លៃទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មីតាមគោលដៅមាន៖ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តស្វាយរៀង ដើម្បីពិនិត្យមើលលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ដែលជាលក្ខខណ្ឌធ្វើឱ្យប្រតិបត្តិការសាលារៀនទទួលបានជោគជ័យ និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់គុណភាពដល់សាលារៀនដែលបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់។

ការវាយតម្លៃនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារថវិកាវិនិយោគរបស់សហគមន៍ និងរាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព ហើយធានាថាការវិនិយោគនេះចំគោលដៅ និងបម្រើផលប្រយោជន៍ដល់លទ្ធផលសិក្សារបស់សិស្ស។ ការវាយតម្លៃនេះក៏ជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការរក្សាបាននូវអភិបាលកិច្ចល្អរបស់សាលារៀន ជាពិសេសគណនេយ្យភាពសាលារៀន និងនវានុវត្តន៍។ អនុគណៈកម្មការវាយតម្លៃទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មី មានសមាសភាពចម្រុះមកពីដៃគូមិនមែនរដ្ឋ មន្ត្រីដឹកនាំមកពីនាយកដ្ឋានពាក់ព័ន្ធនានាមករបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយត្រូវបានចាត់តាំងដោយប្រធានក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មី ថ្នាក់ជាតិ៕(ដកស្រង់ចេញពីផេក New Generation School)

# កសាងមូលធនមនុស្សចាំបាច់ត្រូវការសិស្សមានគុណភាព



សាលារៀនជំនាន់ថ្មីសិស្សមានឧបករណ៍ប្រើប្រាស់គ្រប់គ្រងសម្រាប់ឱ្យសិស្សធ្វើការពិសោធន៍។

សាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ ជាសាលារៀនគំរូមួយ ដែលក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តរបៀបរៀន និងបង្រៀនតាមកម្មវិធីសិក្សាបែបទំនើប ឆ្លើយតបនឹងរបត់នៃការអប់រំនៅក្នុងសតវត្សទី២១ ។ ម្ដាយឪពុក និងអ្នកអាណាព្យាបាលសិស្ស បានចាត់ទុកការអប់រំនៅទីនេះ កំពុងជួយឱ្យកូនៗរបស់គាត់ភាគច្រើនមានចំណេះដឹងទូលំទូលាយ និងសមត្ថភាពប្រកួតប្រជែងខ្ពស់ ។

ទន្ទឹមនឹងការពង្រឹងគុណភាពអប់រំនៅសាលារៀនជំនាន់ថ្មីនេះ លោក សម្ស កំសាន្ត នាយករងវិទ្យាល័យព្រះស៊ីសុវត្ថិ ទទួលបន្ទុកសាលារៀនជំនាន់ថ្មី មានប្រសាសន៍ថា **“សាលារៀនជំនាន់ថ្មី (NGS) មានបេសកកម្មកសាងសមត្ថភាពធនធនមនុស្សនៅកម្រិតវិទ្យាល័យឱ្យក្លាយជាមូលធនមនុស្ស ហើយការកសាងមូលធនមនុស្សចាំបាច់ត្រូវការសិស្សមានគុណភាព”** ។ លោក បានបន្តឱ្យដឹងទៀតថា **“សាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិបានក្លាយជាថ្នាលអប់រំ និងបណ្តុះបណ្តាលសិស្សតាមបែបសតវត្សទី២១ ដែលជួយឱ្យសិស្សានុសិស្សមានសមត្ថភាពចេះត្រិះរិះពិចារណា បង្កើតគំនិតច្នៃប្រតិដ្ឋ បង្កើតកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនង ពង្រីកសក្តានុពលសិស្សកម្រិតវិទ្យាល័យ បណ្តុះគំនិតសហគ្រិនភាព ព្រមទាំងកសាងភាពជាអ្នកដឹកនាំដល់សិស្ស។** លោកបានបន្តថា **“ប្រសិនបើយើងចង់បានកាំបិតមុត ទី១ ទាមទារឱ្យយើងរើសដែកល្អ ទី២ ទាមទារឱ្យយើងមានជាងចំណានដើម្បីមកលត់ដំដែក! ដូចគ្នានេះដើម្បីទទួលបានគុណភាពពីការអប់រំ យើងចាំបាច់ត្រូវការសិស្សមានគុណភាព ពោលគឺសិស្សចូលចិត្តរៀនសូត្រ និងជាសិស្សដែលអប់រំបាន!មួយវិញទៀតយើងត្រូវការគ្រូបង្រៀនដែលមានគុណភាពដូចគ្នា”** ។

គណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិបានបញ្ជាក់ថា សិស្សមករៀននៅសាលារៀនជំនាន់ថ្មី មិនមែនសាលាជ្រើសរើសយកតែសិស្សមានគុណភាព ឬមានសមត្ថភាពស្រាប់មកផ្តល់ការអប់រំឱ្យនោះទេ ប៉ុន្តែសាលារៀនទទួលសិស្សដែលមានការប្តេជ្ញាចិត្តខ្ពស់លើការសិក្សា រួចហើយបង្ហាត់បង្រៀនពួកគេតាមរយៈកម្មវិធីសិក្សាដែលសាលាបានរៀបចំឡើងឆ្លើយតបនឹងតម្រូវការ និងការរីកចម្រើនសង្គម ។ ដូចដែលបានដឹងហើយថា ជារៀងរាល់ឆ្នាំមានសិស្សជាច្រើនដែលចង់ចូលរៀននៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី ប៉ុន្តែសាលារៀនទទួលសិស្សមានចំនួនកំណត់ដោយសារកម្មវិធីមានគោលការណ៍ត្រឹមត្រូវក្នុងការជ្រើសរើសសិស្ស។

ជុំវិញបេសកកម្មកសាងសមត្ថភាពសិស្សនេះ សាលារៀនជំនាន់ថ្មីបានលើកទឹកចិត្តឱ្យសិស្សដែលមកសិក្សាគ្រប់រូបត្រូវបំពេញតួនាទីជាសិស្សល្អ ជាកូនល្អ និងជាពលរដ្ឋល្អក្នុងសង្គម តាមរយៈការអប់រំចំណេះដឹង ការបណ្តុះជំនាញ និងការអប់រំឥរិយាបថរស់នៅប្រចាំថ្ងៃ ។

សិស្សានុសិស្សសាលារៀនជំនាន់ថ្មីត្រូវមានវិន័យក្នុងការសិក្សាដោយគោរពម៉ោងពេលសិក្សាជាក់លាក់តាមកាលវិភាពដែលសាលាបានរៀបចំ **សូមអានបន្តទំព័រ៦...**



លោក សម្ស កំសាន្ត នាយករងសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ។



កម្មវិធីសាលារៀនជំនាន់ថ្មី សិស្សរៀនទ្រឹស្តីផ្សាភ្ជាប់ជាមួយនឹងការអនុត្តដាក់ស្តែងដែលធ្វើឱ្យសិស្សឆាប់ចាប់បានខ្លឹមសារមេរៀន។

**...តពីទំព័រ៥** ហើយក្នុងមួយថ្ងៃសិស្សមានម៉ោងសិក្សាពីរវេន (ព្រឹក និងរសៀល) ។ ការអប់រំរបៀបសិស្សមជ្ឈមណ្ឌលនៅទីនេះ សិស្សម្នាក់ៗត្រូវធ្វើដំណើរទៅថ្នាក់រៀននីមួយៗតាមកាលវិភាគដោយខ្លួនឯង និងមានគ្រូជាអ្នកសម្របសម្រួលតាមជំនាញ និងតាមទេពកោសល្យ បូករួមការទទួលបានវគ្គបណ្តុះបណ្តាលបន្ថែមពីកម្មវិធី ធ្វើឱ្យពួកគាត់មានវិធីសាស្ត្របង្រៀនសម្បូរបែបសម្រាប់បង្រៀនសិស្ស។

គួររម្លឹកផងថា សាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រះស៊ីសុវត្ថិ ជាសាលារៀនស្ថិតនៅក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ សាលារៀននេះ បានសម្ពោធដាក់ឱ្យដំណើរការ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ បានរៀបចំកម្មវិធីសិក្សា និងបន្ទប់សិក្សាដាច់ដោយឡែកពីគ្នាប្រកបដោយផាសុកភាព និងមានភាពងាយសម្រួលដល់ការសិក្សា អមដោយការបំពាក់សម្ភារៈសិក្សាទំនើប និងមានបណ្ណាល័យទំនើបបម្រើដល់ការស្រាវជ្រាវ ។

គណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មីបានចាត់ទុកការអប់រំតវិយាបថ សីលធម៌ និងសុជីវធម៌ របស់បុគ្គលគ្រប់រូប ជាផ្នែកសំខាន់សម្រាប់ការអប់រំ និងដំណើរការសកម្មភាពការងារផ្សេងៗរបស់សាលារៀនទាំងមូល។ ទន្ទឹមគ្នានេះដែរ វិធីសាស្ត្រអប់រំ និងការដោះស្រាយបញ្ហាដោយភាពឆ្លាតវៃ ជាអាទិភាពពិសេសដែលសាលារៀនជួយគាំទ្រសិស្សឱ្យមានការគិតវិជ្ជមាន ព្រមទាំងបង្ហាញពីសីលធម៌ និងសុជីវធម៌ល្អរបស់សិស្ស។

កម្មវិធីសាលារៀនជំនាន់ថ្មីប្រតិបត្តិដោយអង្គការខេប ទទួលហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតសាលារៀនសាធារណៈស្វយ័តមួយមានសិទ្ធិច្នៃប្រឌិត និងកែលម្អគុណភាពអប់រំ ហើយយផ្តោតទៅលើស្តង់ដារវិជ្ជាជីវខ្ពស់ និងអភិបាលកិច្ចល្អ។(អត្ថបទដកស្រង់ចេញពីគេហទំព័រ AMS https://education.ams.com.kh/education-update/national/news/new-generation-school-building-capital-people-need-quality-students/)



សេវាប្រឹក្សាអាជីពជួយឱ្យសិស្សានុសិស្សជ្រើសរើសជំនាញបានត្រឹមត្រូវទៅអនាគតដោយផ្អែកលើបុគ្គលិកលក្ខណៈ។

អនុវិស័យទី ២

# បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍សម្រាប់ការអប់រំ

"បច្ចេកវិទ្យានឹងមិនអាចជំនួសគ្រូដ៏ឆ្នើមៗបានទេ ប៉ុន្តែគ្រូឆ្នើមៗក៏មិនអាចអត់បច្ចេកវិទ្យាសម្រាប់បរិវត្តកម្មបានដែរ"

# Information and Communication Technology (ICT) in Education

*Technology will never replace great teachers, but in the hands of great teachers, it's transformational*



# ការចុះចួបសិស្សានុសិស្សក្នុងការធ្វើតេស្តEGRA



ការចុះប្រមូលទិន្នន័យនៅសាលារៀនគោលដៅ ដើម្បីសិក្សាពីផលជះរបស់គម្រោងលើការសិក្សារបស់កុមារ។

គម្រោងកុមារកម្ពុជារីករាយ (HCC) បានសហការជាមួយសាលារៀនគោលដៅក្នុងការរៀបចំសកម្មភាពចុះចួបនាយក អាណាព្យាបាលសិស្ស សិស្សានុសិស្ស និងការធ្វើតេស្ត EGRA (ចុងឆ្នាំ) តាមសាលារៀននីមួយៗ ក្នុងគោលបំណងឆ្លុះបញ្ចាំងពីផលជះវិជ្ជមាន និងចំណុចត្រូវកែលម្អក្នុងការអនុវត្តសកម្មភាពការងារ ព្រមទាំងរៀបចំផែនការ និងយុទ្ធសាស្ត្រ ក្នុងការគាំទ្រសកម្មភាពសាលារៀនសម្រាប់ការបន្តអនុវត្តគម្រោងក្នុងឆ្នាំសិក្សាថ្មី។

សកម្មភាពចុះជួបនាយក អាណាព្យាបាលសិស្ស សិស្សានុសិស្ស និងការធ្វើតេស្តនេះ ធ្វើឡើងចាប់ពីថ្ងៃទី១១ ហូតដល់ទី១៨ ខែមករា ឆ្នាំ២០២៣ នៅតាមសាលារៀនគោលដៅចំនួន៤១របស់គម្រោង ដោយមានសមាសភាពអ្នកចូលរួមពី តំណាងមន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុកនាយក នាយករង អាណាព្យាបាល និងសិស្សានុសិស្ស។

គម្រោងបានយកចិត្តទុកក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមនានា ដែលសិស្សានុសិស្ស និងសាលារៀនគោលដៅបានជួបប្រទះកន្លងមក ដើម្បីលើកកម្ពស់ និងពង្រឹងការអប់រំឱ្យមានលក្ខណៈល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។

គួររម្លឹកថា គម្រោងHCCបានចាប់ផ្តើមអនុវត្តន៍សកម្មភាពរបស់ខ្លួនតាំងពីឆ្នាំ ២០១៨ រហូតមកដល់បច្ចុប្បន្ន ដែលទទួលបានហិរញ្ញប្បទានពីមូលនិធិគីនផាន់ ដែលផ្តោតលើការគាំទ្រដល់កុមារនៅតាមសហមន៍ជនបទ និងតំបន់ដាច់ស្រយាល៕

# ជំរុញការប្រើប្រាស់ICTក្នុងវិស័យអប់រំដល់សាលារៀនគោលដៅ

គម្រោងកុមារកម្ពុជារីករាយ(HCC) បានរៀបចំវគ្គបំប៉នបន្ថែមមួយស្តីពី ផ្នែកព័ត៌មានវិទ្យាក្នុងការអប់រំ(ICT) ដែលធ្វើឡើងនៅសាលាបឋមសិក្សាកន្ទួត និងសាលាបឋមសិក្សាច្រករំដេង កាលពីថ្ងៃទី១៩-២០ និងថ្ងៃទី២៧-២៨ ខែមេសា ឆ្នាំ២០២៣។ សិក្ខាកាមចូលរួមសរុបចំនួន៤០ នាក់ រួមមាន៖ នាយក នាយករង និងលោកគ្រូអ្នកគ្រូ ដែលមកពីសាលារៀនគោលដៅចំនួន១១ ក្នុងខេត្តត្បូងឃ្មុំ។

វគ្គបំប៉ននេះ មានគោលបំណងផ្តល់ឱ្យសិក្ខាកាម៖១)ស្គាល់ពីធាតុផ្សំមួយចំនួនរបស់កុំព្យូទ័រ (Hardware និង Software)។ ២)ពង្រឹងសមត្ថភាពបន្ថែមលើការប្រើប្រាស់គន្លឹះងាយៗពីកម្មវិធី Excel។ ៣)កសាងសមត្ថភាពសិក្ខាកាមលើការប្រើប្រាស់ Google Drive, Google Forms, Google Sheet និងស្វែងយល់លម្អិតពីចំណុចនីមួយៗឱ្យបានត្រឹមត្រូវ។ សិក្ខាកាមទទួលបានចំណេះដឹងល្អៗជាច្រើនលើការប្រើប្រាស់បច្ចេកវិទ្យាសំខាន់ៗមួយចំនួនដូចជា កិច្ចការរដ្ឋបាល បង្កើនវិធីសាស្ត្របង្រៀនបែបច្នៃប្រតិដ្ឋជាមួយបរិយាកាសរីករាយ និងមានសកម្មភាពថ្មីៗដើម្បីទាក់ទាញកុមារផ្តោតសំខាន់លើការសិក្សារបស់ពួកគេ។ ដូច្នេះគម្រោងតែងតែគាំទ្រ ជំរុញ និងលើកទឹកចិត្តដល់លោកគ្រូអ្នកគ្រូក្នុងការស្រាវជ្រាវព័ត៌មាននៅលើបណ្តាញសង្គមដើម្បីអភិវឌ្ឍន៍ការបង្រៀនឱ្យមានភាពល្អប្រសើរឡើង។

គម្រោងកុមារកម្ពុជារីករាយ ទទួលបានហិរញ្ញប្បទានពីមូលនិធិគីនផាន់ ប្រតិបត្តិដោយអង្គការខេប៕



កសាងសមត្ថភាពលោកគ្រូអ្នកគ្រូលើវិធីសាស្ត្របង្រៀន និងរៀន ជាសកម្មភាពដ៏សំខាន់មួយរបស់គម្រោង។

# តើអ្វីទៅជា WeThinkDigital?



ម៉ូឌុលនីមួយៗត្រូវបានបកប្រែនឹងកែសម្រួលជាភាសាខ្មែរដើម្បីឱ្យការបង្រៀន និងរៀនមានភាពងាយស្រួល។

កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ(KDLP) បានរៀបចំកិច្ចពិគ្រោះយោបល់លើកមួយស្តីពី WeThinkDigital នៅសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប រាជធានីភ្នំពេញ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១២នាក់ ជាគ្រូបង្រៀនផ្នែកព័ត៌មានវិទ្យាប្រចាំនៅតាមសាលារៀនជំនាន់ថ្មីទាំងអស់កាលពីថ្ងៃទី២៦-២៧ ខែមេសា ឆ្នាំ២០២៣។

កិច្ចពិគ្រោះយោបល់នេះ ធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម៖ ១-ពិនិត្យមើលរួមគ្នា និងជ្រើសរើសធនធានសិក្សាចេញពីកម្មវិធី WeThinkDigital (WTD) ដែលត្រូវយកមកប្រើក្នុងបរិបទសាលារៀនជំនាន់ថ្មី។ ២-សិក្សាពីបរិបទ និងបែងចែកធនធានសិក្សាពី WTD សម្រាប់អនុវិទ្យាល័យតាមកម្រិតថ្នាក់។ ៣-បង្កើតកញ្ចប់ធនធានពេញលេញនៃវគ្គសិក្សាអក្ខរកម្មឌីជីថលដែលអាចត្រូវបានសាកល្បងនៅក្នុងសាលារៀនជំនាន់ថ្មីនិងត្រូវបានប្រើប្រាស់នៅក្នុងសាលារដ្ឋនាពេលខាងមុខ។

WTD គឺជាបណ្តុំមេរៀនខ្លីៗ ឬម៉ូឌុលសិក្សាដែលជួយឱ្យមនុស្សចេះគិតពិចារណា និងចែករំលែកព័ត៌មាននៅលើប្រព័ន្ធអនឡាញប្រកបដោយភាពត្រឹមត្រូវ និងអាចជឿជាក់បាន។

សិក្ខាកាមបានពិភាក្សា និងពិនិត្យទៅលើធនធានសិក្សាពីកម្មវិធីWTD ដែលត្រូវបានជ្រើសរើសសម្រាប់ការអភិវឌ្ឍន៍ជាកញ្ចប់ធនធានសិក្សា ដែលមានប្រាំមួយ ម៉ូឌុលរួមមាន៖ ១)ការណែនាំអំពីការរៀនបែបឌីជីថល។ ២)មូលនិធិឌីជីថល។ ៣) សុខុមាលភាពឌីជីថល។ ៤) ការផ្សារភ្ជាប់ទៅនឹងពិភពឌីជីថល ៥)ការពង្រឹងអំណាចឌីជីថល និងឱកាសឌីជីថល។

គម្រោងបានរៀបចំកិច្ចពិគ្រោះយោបល់បានចំនួនបួនលើក ចាប់តាំងពីចុងខែមេសា រហូតដល់ពាក់កណ្តាលខែឧសភានេះ ដើម្បីធ្វើការពិនិត្យ និងកែសម្រួលខ្លឹមសារលើម៉ុឌុលនីមួយៗយ៉ាងយកចិត្តទុកដាក់ មុននឹងផ្តល់ចំណេះដឹងទាំងអស់នេះ ទៅដល់សិស្សានុសិស្សប្រមាណ៣០០០ ទៅ ៥០០០នាក់ ក្នុងរយៈពេល៤ខែ នៃការសាកល្បងកម្មវិធីសិក្សាឌីជីថលថ្មីនេះ។

កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ(KDLP) ទទួលបានហិរញ្ញប្បទានពីក្រុមហ៊ុនមេតា (Meta) ដែលមានគោលបំណងក្នុងការផ្តល់សនិទានភាព និងការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា ICT សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៧-៩) នៅក្នុងសាលារៀនជំនាន់ថ្មី៕



សិក្ខាកាមចូលរួមសរុបចំនួន ១២នាក់ ជាគ្រូបង្រៀនផ្នែកព័ត៌មានវិទ្យាប្រចាំនៅតាមសាលារៀនជំនាន់ថ្មីដែលនឹងត្រៀមបង្រៀនកម្មវិធី WeThinkDigital ដល់សិស្សានុសិស្ស។

# បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សា



សិស្សដែលអាចចូលរៀនក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីត្រូវឆ្លងកាត់ការប្រលង ដោយសារតែសាលារៀនមានចំនួនកំណត់ក្នុងការទទួលសិស្សស្របតាមគោលការណ៍របស់ខ្លួន។

កម្មវិធីសាលារៀនជំនាន់ថ្មី គឺជាកម្មវិធីកំណែទម្រង់ប្រព័ន្ធអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលជាមាគ៌ាអភិវឌ្ឍថ្មីមួយនៅក្នុងប្រព័ន្ធអប់រំនាពេលបច្ចុប្បន្នដែលជួយបង្កើតសាលារៀនសាធារណៈស្វយ័ត។ កម្មវិធីសាលារៀនជំនាន់ថ្មី បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងប្រព័ន្ធអប់រំ និងជំរុញការអប់រំតាមបែបឌីជីថល។ បច្ចុប្បន្ននេះ កម្មវិធីសិក្សាសំខាន់ៗដែលទាក់ទងនឹងផ្នែកព័ត៌មានវិទ្យាដែលបានអនុវត្តក្នុងសាលារៀនជំនានថ្មីមានដូចជា៖១) កម្មវិធីគ្រប់គ្រងសាលារៀន NGS Mobile សំដៅលើការគ្រប់គ្រងបញ្ជីទិន្នន័យ ពិន្ទុសិស្ស និងកាតសិស្សដើម្បីដានតាមការសិក្សារបស់សិស្សឱ្យមានភាពល្អប្រសើរឡើង។ កម្មវិធីនេះ កំពុងដំណើរការក្នុងសាលារៀនជំនាន់ថ្មីចំនួន៥។ ២) កម្មវិធីប្រព័ន្ធរំឭកជាមុន (EWS) គឺជាកម្មវិធីមួយដែលប្រើប្រាស់លើការគ្រប់គ្រងបញ្ជី ទិន្នន័យគ្រូ សិស្ស ពិន្ទុ វត្តមាន ឥរិយាបថសិស្ស និងសកម្មភាពផ្សេងៗទៀត។ បច្ចុប្បន្ននេះ កម្មវិធីប្រព័ន្ធរំឭកជាមុន ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បង និងដាក់ដំណើរការនៅសាលារៀនចំនួន៥ (បើដំណើរការជោគជ័យ វានឹងប្រើប្រាស់ជំនួស NGS Mobile)។ ៣) ហ្វេសប៊ុកផេក និងវេបសាយកម្មវិធីសាលារៀនជំនាន់ថ្មីនឹងផ្សព្វផ្សាយសកម្មភាពផ្សេងៗដែលកើតមានឡើងក្នុងសាលារៀនជូនដល់មហាជន។ ៤) កម្មវិធី Game Technology ជាកម្មវិធីសិក្សាថ្មីមួយដែលបានអនុវត្តសាកល្បងនៅវិទ្យាល័យព្រះស៊ីសុវត្ថិលើសិស្សចំនួន៦នាក់។ កម្មវិធីមាន ៨ម៉ូឌុល ក្នុងមួយម៉ូឌុលមាន ៨មេរៀន មួយមេរៀនប្រើពេល ៤ម៉ោង។ ៥)កម្មវិធីអំណានភាសាអង់គ្លេស(X-Reading) គឺជាកម្មវិធីអានពាក្យនៅលើប្រព័ន្ធអនឡាញ ហើយសិស្សអាចដឹងចំនួនពាក្យដែលគេបានអាន។ កម្មវិធីនេះបានជំរុញលើកទឹកចិត្តសិស្សសរុប ៥៣៨ នាក់ បន្ថែមលើការសិក្សាទាំងភាសាខ្មែរ និងភាសាអង់គ្លេសដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបដើម្បីវាស់ស្ទង់ និងតាមដានសមត្ថភាពពួកគាត់។

កម្មវិធីសាលារៀនជំនាន់ថ្មីមានកម្មវិធីសិក្សាថ្មីៗជាច្រើនផ្សេងទៀតដែលជួយឱ្យសិស្សមានការយល់ដឹងកាន់តែទូលំទូលាយក្នុងវិស័យបច្ចេកវិទ្យាតាមរយៈការអនុវត្តគម្រោងតូចៗនៅក្នុងថ្នាក់ ហើយសិស្សានុសិស្សនឹងធ្វើការដាក់តាំងបង្ហាញស្នាដៃពីអ្វីដែលពួកគេរៀនបានដល់អាណាព្យាបាល សិស្ស មហាជន ដែលសាលារៀននឹងរៀបចំឡើងជារៀងរាល់ឆ្នាំ៕



សិស្សមានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងដឹកនាំគម្រោងតូចៗដោយមានការគាំទ្រពីលោកគ្រូអ្នកគ្រូ។

អនុវិស័យទី ៣

# ការអភិវឌ្ឍគ្រូបង្រៀន

"គ្រូដែលល្អមិនមែនគ្រាន់តែជាអ្នកប្រាប់ ជាអ្នកពន្យល់ និងបង្ហាញនោះទេ តែជាអ្នកជំរុញលើកទឹកចិត្តសិស្ស"

## Teacher Development

*The mediocre teacher tells. The good teacher explains.*
*The superior teacher demonstrates. The great teacher inspires.*



# ទស្សនៈកិច្ចសិក្សាគ្រូកិច្ចសន្យាថ្មើមប្រចាំគម្រោងជំនាន់ទី១



ការផ្លាស់ប្តូរបទពិសោធន៍សិក្សាតាមរយៈទស្សនកិច្ច បានជំរុញឱ្យសិក្ខាកាមកែលម្អចំណុចខ្វះខាតលើការបង្រៀន។

គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំកម្មវិធីទស្សនៈកិច្ចសិក្សាគ្រូកិច្ចសន្យាថ្មើមប្រចាំគម្រោងជំនាន់ទី១ ដែលធ្វើឡើងនៅ សាលាបឋមសិក្សា គួច ម៉េងលី ទួលបេង ដែលស្ថិតក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមករា រហូតដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣។ សមាសភាពអ្នកចូលរួមដូចជា ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកកំពង់សៀម គ្រូប្រឹក្សាគរុកោសល្យ លោកនាយក នាយករង និងគ្រូកិច្ចសន្យាថ្មើមចំនួន ១៨ នាក់ ដែលមកពីខេត្តចំនួនបី រួមមាន៖ ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ និងខេត្តសៀមរាប។ ទស្សនកិច្ចនេះ មានគោលបំណងផ្តល់ឱ្យសិក្ខាកាមយល់ដឹងនូវវិធីសាស្រ្តបង្រៀនល្អៗ ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការសង្កេតថ្នាក់រៀន និងស្វ័យឆ្លុះបញ្ចាំងអំពីការបង្រៀន និងរៀន។

តាមរយៈទស្សនកិច្ច សិក្ខាកាមទទួលបានចំណេះដឹងល្អៗបន្ថែមក្នុងការបង្រៀន និងរៀនធ្វើសិស្សឱ្យទទួលបានលទ្ធផលការសិក្សាប្រសើរឡើង ព្រមទាំងចែករំលែកនូវអ្វីដែលខ្លួនបានរៀនសូត្រដល់គ្រូដទៃទៀត។ គម្រោងមិនត្រឹមតែផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូកិច្ចសន្យាប៉ុណ្ណោះទេ ថែមទាំងចុះទៅជួយបំប៉នបន្ថែមផ្សេងៗដល់លោកគ្រូអ្នកគ្រូក្នុងការបង្រៀនសិស្សប្រកបដោយក្របសីលធម៌។

គម្រោងHCCទទួលបានហិរញ្ញប្បទានពីមូលនិធិគីនធាន់ ធ្វើការពង្រឹងសេវាអប់រំកាន់មានភាពល្អប្រសើរឡើងនៅតាមសាលារៀនគោលដៅ៕

# ការគ្រប់គ្រងថ្នាក់រៀន ពិតជាសំខាន់សម្រាប់ទាក់ទាញសិស្ស

គម្រោងកុមារកម្ពុជារីករាយ(HCC) បានរៀបចំវគ្គសិក្ខាសាលាមួយស្តីពី ការគ្រប់គ្រងថ្នាក់រៀន នៅសាលាបឋមសិក្សាទូយ ដើម្បីបណ្តុះបណ្តាលដល់គ្រូបង្រៀនថ្នាក់ទី១ ដល់ទី៦ ឱ្យបានស្វែងយល់អំពីវិធីសាស្រ្តគ្រប់គ្រងថ្នាក់រៀន ការគ្រប់គ្រងសិស្ស



លោកគ្រូអ្នកគ្រូពិភាក្សា និងចែករំលែកមតិយោបល់លើការគ្រប់គ្រងថ្នាក់រៀនដែលជាផ្នែកមួយសំខាន់ក្នុងការបង្រៀន។

ដើម្បីកែលម្អគុណភាពបង្រៀន និងរៀនមានសកម្មភាពរស់រវើក និងល្អប្រសើរ។

វគ្គសិក្ខាសាលានេះ ធ្វើឡើងកាលពីថ្ងៃទី១៣-១៤ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន ៤៩ នាក់ (ស្រី ១៤នាក់)រួមមាន៖តំណាងខាងមន្ទីរ-ការិយាល័យអប់រំយុវជន និងកីឡាខេត្ត-ស្រុក និងលោកគ្រូអ្នកគ្រូដែលមកពីសាលារៀនគោលដៅចំនួន១២ ក្នុងខេត្តរតនគិរី។

សិក្ខាកាមទទួលបានចំណេះដឹងល្អៗបន្ថែមលើការគ្រប់គ្រងថ្នាក់រៀន បានស្វែងយល់ពីមូលហេតុមួយចំនួនដែលនាំឱ្យសិស្សមានអាកប្បកិរិយាមិនល្អ ភាពខុសគ្នារបស់កុមារ វិន័យបែបវិជ្ជមានក្នុងការបង្រៀន និងរៀន ព្រមទាំងការគ្រប់គ្រងពេលវេលា ដើម្បីជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ៕

# ការអភិវឌ្ឍភាពជាអ្នកដឹកនាំដល់ជាមន្ត្រីក្រសួងអប់រំ



ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមជាក្រោមធិបតីភាព នៅសាលប្រជុំសាលារៀនជំនាន់ថ្មីវិទ្យាល័យហ៊ុន សែនកំពង់ចាម ធ្វើការបិទបញ្ចប់វគ្គបណ្ដុះបណ្ដាលការអភិវឌ្ឍភាពជាអ្នកដឹកនាំ។

កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ ដល់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រៀបចំឡើងដោយអង្គការមូលនិធិអាស៊ី និងដៃគូប្រតិបត្តិជាមួយអង្គការខេប បានរៀបចំវគ្គបណ្ដុះបណ្ដាលមួយស្ដីពី **ការអភិវឌ្ឍភាពជាអ្នកដឹកនាំ** ក្រោមធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំសាលារៀនជំនាន់ថ្មីវិទ្យាល័យហ៊ុន សែនកំពង់ចាម ដោយមានសិក្ខាកាមសរុបចំនួន ៨០នាក់ ជាមន្ត្រីក្រសួងអប់រំ និងអង្គការដៃគូ។

កម្មវិធីនេះ ប្រព្រឹត្តឡើងចាប់ពីថ្ងៃទី ១៣ ដល់ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ក្នុងគោលបំណងផ្ដល់នូវចំណេះដឹង និងជំនាញដល់សិក្ខាកាមដែលផ្ដោតទៅលើ៖ ១-ទស្សនទាននៃភាពជាអ្នកដឹកនាំជាមូលដ្ឋានគ្រឹះ។ ២-ជំនាញទំនាក់ទំនងដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងមូលដ្ឋានគ្រឹះនៃការផ្ដល់ប្រឹក្សាណែនាំដើម្បីគាំទ្រដល់ការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័រ ក៏ដូចជាបរិយាបន្នសង្គម។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បានមានប្រសាសន៍ថា “**ការបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំពិតជាសំខាន់ ដើម្បីបណ្ដុះ និងបង្រៀនដល់អ្នកជំនាន់ក្រោយសម្រាប់បន្តវេនរបស់ខ្លួន។ តួយ៉ាងអង្គភាពនីមួយៗត្រូវមានបេសកម្មឱ្យបានច្បាស់លាស់ ពង្រឹងសមត្ថភាព និងប្រព័ន្ធគ្រប់គ្រងឱ្យបានត្រឹមត្រូវដើម្បីជួយគាំទ្រដល់ការកែលម្អសាលារៀន។ ដូច្នេះ គ្រប់អង្គភាពទាំងអស់ត្រូវជំរុញឱ្យបុគ្គលិកបន្តការរៀនសូត្រនូវអ្វីដែលថ្មី ដើម្បីពង្រីកឱ្យគិតឱ្យទូលំទូលាយ**”។

កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ បានលើកកម្ពស់សមត្ថភាពក្នុងចំណោមអ្នកដឹកនាំកម្រិតថ្នាក់កណ្ដាលរបស់ក្រសួងអប់រំ ដើម្បីយកចំណេះដឹងថ្មីៗដែលទទួលបានទៅអនុវត្តន៍ក្នុងមុខតំណែងវិជ្ជាជីវៈរបស់ពួកគាត់។ ម៉្យាងទៀត ការផ្ដល់ការអភិវឌ្ឍសមត្ថភាពជាក់លាក់ ដើម្បីបំពេញសេចក្ដីត្រូវការរបស់ស្ត្រីក្នុងតួនាទីដឹកនាំនៅការិយាល័យខេត្តគោលដៅ។

កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹក គឺជាធាតុផ្សំដ៏សំខាន់មួយដែលចាំបាច់ដើម្បីសម្រេចបាននូវការប្ដេជ្ញាចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធានាឱ្យមានធនធានមនុស្សដែលប្រកបដោយបរិយាបន្ន និងមានសមត្ថភាពគ្រប់គ្រង និងដឹកនាំប្រកបដោយប្រសិទ្ធភាពនៅក្នុងក្រសួង៕



# ការសិក្សាផ្នែកទំនាក់ទំនងជាលក្ខណៈវេទិកា




សិក្ខាកាមទទួលបានព័ត៌មានសំខាន់ៗពីការសិក្សាផ្នែកទំនាក់ទំនងជាលក្ខណៈវេទិកា និងវិធីសាស្រ្តមួយចំនួនអំពីការរូបថតសម្រាប់ប្រើប្រាស់ក្នុងរបាយការណ៍របស់គម្រោង។

គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម( CO-SAVED) បានរៀបចំជាសិក្ខាសាលាអំពីការអភិវឌ្ឍសមត្ថភាព និងការចងក្រងឯកសារស្ដីពី ការសិក្សាផ្នែកទំនាក់ទំនងជាលក្ខណៈវេទិកា និងបានសម្របសម្រួលដោយអង្គការ Aide et Action (AeA) ឬ Action Education នៅក្នុងខេត្តកែបកាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ដោយមានមន្រ្តីតំណាងមកពីអង្គការ ខេប និងអង្គការ AeA ចូលរួម។

សិក្ខាសាលានេះមានគោលបំណងបង្កើនសមត្ថភាពរបស់អង្គការដៃគូក្នុងការផលិតសម្ភារផ្នែកទំនាក់ទំនង និងពន្លឿនលើកកម្ពស់អង្គការដៃគូទាំងពីរដើម្បីពង្រីកកិច្ចសហប្រតិបត្តិការផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍ផែនការការងារទំនាក់ទំនង និងវិធីទំនាក់ទំនងបែបយុទ្ធសាស្រ្ត។



ការសិក្សាផ្នែកទំនាក់ទំនងជាលក្ខណៈវេទិកា បានធ្វើឱ្យសិក្ខាកាមបានបង្កើនភាពសិទ្ធសាលជាមួយអង្គការដៃគូ។

ការធ្វើឱ្យសេវាផ្តល់ និងទទួលព័ត៌មានទៅ/ពីអ្នកទទួលផល និងអ្នកពាក់ព័ន្ធ ជាពិសេសទៅម្ចាស់ជំនួយមានភាពងាយស្រួល គឺតម្រូវឱ្យមានការប្រើប្រាស់ជារូបថតជាក់ស្តែង មានលក្ខណៈទាក់ទាញ និងត្រូវនឹងសកម្មភាពគម្រោង។ ការជ្រើសរើសទីកន្លែងដែលមានពន្លឺល្អ អនុវត្តតាមច្បាប់ថតរូប (១ភាគ៣នៃរូបភាព) ការកំណត់ទីតាំងសំខាន់ក្នុងរូប (Subject Focus) ថតនៅលើពន្លឺជាដើម។

ជារួមមកវិញ សិក្ខាកាមបានធ្វើយល់ច្បាស់ពីប្រធានបទសម្រាប់ប្រើប្រាស់នៅក្នុងការទំនាក់ទំនងប្រចាំថ្ងៃ ព្រោះទំនាក់ទំនងល្អគឺជាការផ្តល់សារជាសម្លេង រូបភាព និងវីដេអូទៅវិញទៅមកងាយស្រួលយល់។ ម្យ៉ាងទៀត សិក្ខាកាមក៏បានដឹងពីរបៀបថតរូបសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពគម្រោង។

គម្រោងCO-SAVED ទទួលហិរញ្ញប្បទានពីសហភាពអឺរ៉ុប អង្គការ Aide et Action ដែលធ្វើការនៅតាមសហគមន៍នេសាទនៅតំបន់ឆ្នេរដើម្បីប្រែក្លាយមានជីវភាពរស់រើកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានប្រកបដោយចេរភាព ពង្រឹងការផ្តល់សេវាកម្ម និងអភិវឌ្ឍបៃតង ដែលសំដៅដល់ការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងមានវិសមភាព៕

# ពង្រឹងសមត្ថភាពលើការប្រើប្រាស់កម្មវិធីគ្រូមត្តេយ្យ



សិក្ខាកាមចូលរួមសរុបចំនួន១៤ នាក់ មកពីសាលារៀនគោលដៅចំនួន១១ ពីខេត្តស្វាយរៀង និងខេត្តព្រៃវែង ដើម្បីបង្កើនចំណេះដឹងបន្ថែមពីកម្មវិធីគ្រូមត្តេយ្យសិក្សា។

គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយការគាំទ្រពីសហគមន៍ (REACH IV/BMZ) ទទួលបានហិរញ្ញប្បទានពីអង្គការវីវើល បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តី កម្មវិធីគ្រូមត្តេយ្យសិក្សាកិច្ចសន្យាស្តីពីសៀវភៅសិក្សាគោលទាំង៥ ក្រោមការសម្របសម្រួលដោយ លោកស្រី ទី គុន្ធា មន្ត្រីការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និង កីឡាខេត្តស្វាយរៀង ដែលធ្វើឡើងនៅសាលាមត្តេយ្យសិក្សាធនជានកុមារថ្មី និងមានសិក្ខាកាមចូលរួមសរុបចំនួន ១៤ នាក់ ស្រី ១៤ នាក់ មកពីសាលារៀនគោលដៅចំនួន១១ ពីខេត្តស្វាយរៀង និងខេត្តព្រៃវែង។

វគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងនៅថ្ងៃទី២៧-២៨ ខែមេសា ឆ្នាំ២០២៣ មានគោលបំណងដូចខាងក្រោម៖១-ពង្រឹងសមត្ថភាពគ្រូមត្តេយ្យសិក្សាកិច្ចសន្យា។ ២-បង្ហាញលំនាំបង្រៀនលើមុខវិជ្ជាលើមុខវិជ្ជាទាំង ៥ ការរៀបចំជ្រុងសិក្សា ការរៀបចំថ្នាក់ និងការបង្ហាញគំរូកិច្ចតែងការបង្រៀន និងធ្វើថ្នាក់និទស្សន៍ រំលឹកឡើងវិញ មុខវិជ្ជាទាំង៥ និងតេស្តកុមារ៥ឆ្នាំ និងផែនការបន្ត។

សិក្ខាកាមទាំងអស់ទទួលបានចំណេះដឹងនិងបទពិសោធន៍ល្អៗជាច្រើនដែលអាចយកទៅអនុវត្តន៍លើការប្រើប្រាស់កម្មវិធីសៀវភៅសិក្សាគោលថ្មីលើមុខវិជ្ជាទាំង៥ របស់មត្តេយ្យសិក្សាប្រកបដោយគុណភាព។

គម្រោង REACH/BMZ គឺជាគម្រោងធំមួយទៀតរបស់ខេបដែលប្រើវិធីសាស្ត្រអភិវឌ្ឍន៍រួម ដើម្បីដោះស្រាយទិដ្ឋភាពជាច្រើននៃបរិស្ថានសិក្សារបស់កុមារ រួមទាំងការចូលប្រើប្រាស់ផងដែរនូវ បរិយាកាសសិក្សា ការចូលរួមរបស់សហគមន៍ ការការពារកុមារ។ល។ ដោយស្របតាមគោលការណ៍កម្មវិធីសាលាកុមារមេត្រី៕



លោកស្រី ទី គុន្ធា មន្ត្រីការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និង កីឡាខេត្តស្វាយរៀង ជាអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល។

អនុវិស័យទី ៤

# កម្មវិធីអប់រំបរិយាប័ន្ន

"ភាពចម្រុះ និងការអប់រំបរិយាប័ន្នផ្ដល់តម្លៃដល់មនុស្សគ្រប់រូបមិនថាយើងមានភាពខុសគ្នាយ៉ាងណាក៏ដោយ"។

# Inclusive Education

*Diversity and Inclusion are about giving value to every human being, no matter our differences.*















# ឱកាសផ្លាស់ប្តូរជីវិតកុមារពិការកាយ តែមិនពិការគំនិត



សុខនៅ និងជីដូនរបស់គាត់អង្គុយលើគ្រែឈើ ញញឹមដោយមានសេចក្តីសង្ឃឹម។

កុមារពិការឈ្មោះ សុខនៅ អាយុ ១០ឆ្នាំ កំព្រាឪពុក (ឪពុកមានប្រពន្ធថ្មីតាំងពីគាត់នៅតូចម្លេះ) រស់ជានៅជាមួយម្តាយឈ្មោះ សៅ ស្រីរ៉ា និងជីដូន។ គាត់មានប្អូនចំនួន២នាក់ រស់នៅជាមួយគ្នានៅតំបន់ជនបទ មានចម្ងាយជិត៣គីឡូម៉ែត្រពីសាលារៀន ស្ថិតក្នុងឃុំអន្សោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ម្តាយរបស់គាត់បានបើកមុខរបរលក់ចាប់ហួយនៅក្នុងរយៈពេល៣ឆ្នាំចុងក្រោយ បន្ទាប់ពីឈប់ធ្វើការងារសំណង់នៅភ្នំពេញ។ គាត់រកចំណូលបានពី២,៥ ដល់៥ ដុល្លារក្នុងមួយថ្ងៃ ដែលមានការពិបាកសម្រាប់ផ្គត់ផ្គង់ការរស់នៅ និងចំណីអាហារដល់កូនទាំង៣ ព្រមទាំងម្តាយចាស់ជរាមួយនាក់ទៀតនៅក្នុងបន្ទុក និងសុំដីពីម្តាយគាត់មួយប្រលោះតូចធ្វើតូបលក់ចាប់ហួយ ហើយមិនអាចបញ្ជូនសុខនៅទៅសាលារៀនបានទេ។

បន្ទាប់ពីមានការអន្តរាគមន៍របស់គម្រោងងាយស្រួលរៀន(E2L) ដែលប្រតិបត្តិដោយអង្គការ ខេប ក្រោមជំនួយហិរញ្ញប្បទានពីអង្គការឆាលហ្វានកម្ពុជា និងក្រោយពេលទទួលបានព័ត៌មានផ្សព្វផ្សាយពីលោកនាយក អ្នកស្រី រ៉ា បាននាំយកកូនទៅចុះឈ្មោះចូលរៀន។ សុខនៅបានចុះឈ្មោះចូលរៀននៅថ្នាក់ទី១ សិក្សាលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រសិក្សា។ សាលារៀនមានពីរវេណ ព្រឹកពីម៉ោង ៧.០០ ដល់ ១១.០០ និងពេលរសៀលពីម៉ោង ១.០០ ដល់ម៉ោង ៥.០០។

សុខនៅធ្លាប់ចុះឈ្មោះចូលរៀន ប៉ុន្តែមិនបានទៅសាលារៀន ព្រោះគាត់ខ្វិនជើង គ្មានសម្ភារជួយសម្រួលដល់ការធ្វើដំណើរ និងការសិក្សារបស់គាត់។ ម្យ៉ាងវិញទៀត ម្តាយរបស់គាត់ក្រីក្រ គ្មានលទ្ធភាពទិញរទេះរុញឱ្យជិះទៅសាលារៀនបាន។ សុខនៅត្រូវបង្ខំវា និងលូននៅផ្ទះ គ្មានការលើកទឹកចិត្ត មានអារម្មណ៍ខ្លាចគេឯង។ ជីដូនរបស់គាត់ជួយគ្រា និងផ្តល់អាហារឱ្យក្នុងពេលម្តាយគាត់ជាប់ធ្វើការងារសំណង់។ សុខនៅប្រកាច់ញ័រខ្លួនពីរដងក្នុងមួយឆ្នាំ។ បច្ចុប្បន្ននេះ សុខនៅមានសេចក្តីសប្បាយចិត្តច្រើន ដោយសារមានឱកាសទៅសាលារៀន និងចូលរួមសកម្មភាពផ្សេងៗជាមួយសិស្សដទៃទៀត។ សុខនៅបាននិយាយថា **"ខ្ញុំសប្បាយរីករាយណាស់ដោយបានចូលរៀនដូចគេ។**

**សូមអានបន្តទំព័រ១៨...**



សុខនៅ និងម្តាយគាត់ឈរនៅមុខតូបលក់ចាប់ហួយ ដែលជាផ្ទះរបស់ពួកគាត់រស់នៅប្រចាំថ្ងៃ។




តពីទំព័រ១៧... ខ្ញុំចង់ក្លាយទៅជាអ្នកជំនាញផ្នែកលក់ និងជួសជុលទូរសព្ទ ព្រោះវាងាយស្រួលសម្រាប់ខ្ញុំ។ ដូច្នេះ ខ្ញុំនឹងខិតខំយកចិត្តទុកដាក់រៀនសូត្រឱ្យបានល្អ”។

ក្រោយពីមានអន្តរាគមន៍របស់គម្រោង E2L ដល់សាលាបឋមសិក្សាក្រើល លទ្ធផលសិក្សារបស់សុខនៅមានភាពប្រសើរឡើង គាត់ក្លាហាននិយាយជាមួយសិស្សដទៃ និងចូលរួមលេងល្បែងសិក្សាជាមួយមិត្តនៅសាលា។ ម្តាយសុខនៅបានជូនគាត់ទៅសាលារៀនរាល់ថ្ងៃ ទាំងវេណព្រឹក និងការរៀនបំប៉នពេលរសៀល។ លោក **វន្ត ហឿន** នាយកសាលាបឋមសិក្សាក្រើល បានមានប្រសាសន៍ថា “**កុមារសុខនៅទទួលបានការលើកទឹកចិត្ត និងឱកាសចុះឈ្មោះចូលរៀនដូចសិស្សដទៃទៀត ហើយគាត់សប្បាយចិត្តខ្លាំងដោយបានស្គាល់មិត្តភក្រផ្សេងៗ និងមិនខ្លាច ឬខ្មាស់អៀនដូចមុន។ គាត់មកសាលារៀនទៀងទាត់ជាងមុន ហើយបើគម្រោងមិនជួយគាត់ទេ គាត់មិនបានមកសាលារៀនទេ**”។

លោកយាយ **ប្រាក់ ភាព** គឺជាជីដូនរបស់សុខនៅ ដែលកំពុងអង្គុយជិតចៅលើគ្រែក្នុងតូបចាប់ហ៊ួយកូនគាត់ បានមានប្រសាសន៍ក្នុងទឹកមុខរីករាយថា "**កាលពីមុនចៅខ្ញុំសុខនៅមិនចេះអីសោះ សូម្បីអក្សរក៏មិនចេះសរសេរ និងអានបានដែរ។ ប៉ុន្តែបច្ចុប្បន្ននេះ វាចេះសរសេរ និងចេះអានប្រសើរជាងមុន**"។

សុខនៅបានបន្តខិតខំសិក្សាដោយមានការលើកទឹកចិត្តពីជីដូន និងអ្នកម្តាយ ជាពិសេសលោកនាយក និងគ្រូទទួលបន្ទុកថ្នាក់។ សុខនៅមានការផ្លាស់ប្តូរច្រើន ដូចជាឈប់មានអារម្មណ៍ខ្លាចគេឯង អាចអាន សរសេរ និងធ្វើលំហាត់គណិតវិទ្យាបាន។ គាត់បានទៅសាលា និងខិតរៀនសូត្រជារៀងរាល់ថ្ងៃ។ អ្នកស្រី រ៉ា បានមានប្រសាសន៍ថា “**ទោះបីជាគម្រោងឈប់បន្តជួយ នាងខ្ញុំនៅតែខិតខំលក់ដូរតិតក់ៗដើម្បីជំរុញឱ្យកូនបានទៅរៀនបន្តទៀត**”។

លោក ម៉ែន ធី មន្ត្រីគម្រោងងាយស្រួលរៀនបានលើកឡើងថា “**ការផ្តល់ឱកាសទទួលបានសេវាអប់រំពេញលេញដល់កុមារដែលមានពិកាភាព គឺជាការផ្តល់ឱកាសដល់ពួកគេនូវជីវិតរស់នៅដ៏ល្អប្រសើរមួយ**”។

អង្គការ ខេប សម្រេចបានជោគជ័យជាច្រើនលើការប្រតិបត្តិគម្រោងអប់រំដល់កុមារ និងយុវជនរយៈពេលជាង២០ឆ្នាំកន្លងមកនេះ។ អង្គការបានជួយបន្តពង្រឹងគុណភាពគ្រូ និងនាយកសាលា ក្នុងការបង្រៀន ការគ្រប់គ្រងសាលា ធ្វើសមាហរណកម្មកម្មវិធីអប់រំបរិយាបន្នរវាងកុមារ និងយុវជនទៅនឹងគ្រួសាររបស់ពួកគេនៅក្នុងសង្គមកម្ពុជា។ អង្គការ ខេប នៅតែបន្តស្វែងរកដៃគូអភិវឌ្ឍន៍ផ្សេងៗ ដែលអាចឆ្លើយតបនឹងតម្រូវការយុវជន និងកុមារដែលមានពិការភាពនិងងាយរងគ្រោះ។ ក្រៅពីការផ្តល់ជាកម្មវិធីអាហារូបករណ៍ជាសម្ភារបង្រៀន និងរៀន អង្គការក៏មានកម្មវិធីបញ្ជូនកុមារដែលមានជំងឺទៅព្យាបាលនៅមន្ទីរពេទ្យផងដែរ។ អង្គការ ខេប បានធ្វើការងារជាមួយអង្គការឆាលហ្វានកម្ពុជា និងដៃគូចម្រុះដទៃទៀត រួមមាន៖ ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋាភិបាលថ្នាក់ក្រោមជាតិ សាលារៀន សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធជាច្រើនទៀត។ កុមារពិការ សុខនៅ ត្រូវការបន្តលើកទឹកចិត្តទាំងកលាំងកាយ និងស្មារតី ឱ្យគាត់បានសប្បាយចិត្តខំរៀន និងមានសេចក្តីសង្ឃឹមនៅក្នុងជីវិត៕

# កុមារីងាយរងគ្រោះបានប្ដូរពន្លឺមាគ៌ាជីវិតថ្មី



អ្នកស្រី ម៉ៅ និងកូនស្រី រក្សា អង្គុយនៅផ្ទះបងរបស់គាត់ពោរពេញទៅដោយស្នាមញញឹមនៃក្ដីសង្ឃឹមអំឡុងពេលមានការជួយជ្រោមជ្រែងពីគម្រោងងាយស្រួលរៀន។

កុមារីឈ្មោះ អាង រក្សា អាយុ១៣ឆ្នាំ ជាសិស្សថ្នាក់ទី៦ រស់ជានៅជាមួយម្ដាយឈ្មោះ កាន់ ស្រីម៉ៅ និងឪពុកឈ្មោះ វន្ត ធាន ក្នុងភូមិជនបទមួយ មានចម្ងាយប្រមាណជា៣គីឡូម៉ែត្រពីសាលាបឋមសិក្សាទួលរកា ស្ថិតក្នុងឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឪពុកជាកម្មករសំណង់ និងម្ដាយជាមេផ្ទះគ្មានមុខរបរដាក់លាក់រកចំណូលបន្ថែមទេ។ រក្សាមានប្អូនស្រីម្នាក់រៀនថ្នាក់ទី២ គ្រួសារនាងគ្មានផ្ទះល្អសមរម្យរស់នៅទេ ព្រោះបច្ចុប្បន្នគ្រួសារទាំងមូលស្នាក់អាស្រ័យនៅជាមួយជីដូនជីតា។ ឪពុករបស់រក្សាជាបុគ្គលទោលក្នុងការរកចំណូលចិញ្ចឹមគ្រួសារ ដែលចំណូលតិចតួចមិនទៀតទាត់ ពេលណាមានសំណង់ធ្វើ ទើបគេហៅទៅធ្វើ ដែលមានការពិបាកយ៉ាងខ្លាំងសម្រាប់ផ្គត់ផ្គង់ការរស់នៅ និងចំណីអាហារដល់គ្រួសារទាំងមូល។ រក្សាបានទៅសាលារៀនមិនទៀងទាត់ឡើយ ដោយសារមានរោគស្ត្រីប្រចាំកាយ មានធ្លាក់ឈាម និងមានភាពអៀនខ្មាស់មិនហ៊ានប្រាប់ឱ្យឪពុកម្ដាយ ឬគ្រូដឹងឡើយ។ នៅពេលឃើញមានធ្លាក់ឈាម ម្ដាយនាងក៏តែងបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ហើយខានទៅសាលារៀន។

បន្ទាប់ពីមានអន្តរាគមន៍របស់គម្រោងងាយស្រួលរៀន (E2L) ដែលប្រតិបត្តិដោយអង្គការ ខេប ក្រោមជំនួយពីអង្គការឆាលហ្វានកម្ពុជា ម្ដាយរបស់នាងទទួលការអញ្ជើញចូលរួមសម្ភាស និងពិគ្រោះយោបល់នៅសាលារៀនស្ដីពី ការសិក្សារបស់កូនស្រី ជាពិសេសពាក់ព័ន្ធសុខភាពកុមារីពេញវ័យ ដែលកូនស្រីមិនដែលប្រាប់ការពិតដល់ឪពុកម្ដាយ។ ក្រោយមក រក្សាបានទៅសិក្សានៅសាលាបឋមសិក្សាទួលរកា ជាទៀងទាត់ឡើងវិញនូវមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងភាសាអង់គ្លេស។ អ្នកគ្រូ ឈឹម ផល្លនារី ទទួលបន្ទុកផ្នែកប្រឹក្សាកុមារី បានលើកឡើងថា"*តាមរយៈកម្មវិធីប្រឹក្សាកុមារី យើងអាចជួយកុមារីងាយរងគ្រោះបានច្រើននាក់ពីថ្នាក់ទី៤ដល់ទី៦ ជាពិសេសកុមារី រក្សាលែងអៀនខ្មាស់ដូចមុន។ រាល់ពេលមានបញ្ហា នាងតែងតែមកសួរខ្ញុំ នាងមានវត្តមានមកសាលារៀនទៀងទាត់វិញ កាលពីមុននាងជាប់ចំណាត់ថ្នាក់លេខ១០បច្ចុប្បន្នជាប់លេខ៩*"។

កាលពីមុនគម្រោងមិនទាន់ចូលមកអន្តរាគមន៍ រក្សាឧស្សាហ៍អវត្តមានច្រើន ប្រឈមបញ្ហាធ្លាក់ស និងការមករដូវ ឈឺច្រើន អៀនខ្មាស់ មិនហ៊ានប្រាប់ឪពុកម្ដាយ មានអាការៈឈឺចុកពោះ មុខស្លេក ខកខានទៅសាលារៀន។ ម្ដាយតែងតែសួរនាំ និងជូននាងទៅពេទ្យ រីឯការសិក្សារបស់រក្សាមានការធ្លាក់ចុះ។ ក្រោយពេលគម្រោងដាក់បញ្ចូលកម្មវិធីប្រឹក្សាកុមារី **សូមអានបន្តទំព័រ២០...**



រក្សាបានតាំងចិត្តយ៉ាងមុតមាំ និងឆ្លៀតពេលយកចិត្តទុកដាក់ខិតខំសិក្សានៅផ្ទះបន្ថែម អំឡុងពេលសាលារៀនកំពុងវិស្សមកាល។




**តពីបន្តទំព័រ១៩...** សាលារៀនបានអញ្ជើញ អ្នកស្រី ស្រីម៉ៅ ទៅប្រជុំអំពី ការសិក្សានិង បញ្ហាប្រឈមរបស់កូន។ កុមារី រក្សា ក៏ទទួល បានការប្រឹក្សាអំពីបញ្ហាសុខភាព និងការ សិក្សារហូតនាងបានផ្លាស់ប្តូរច្រើន ហ៊ាន និយាយប្រាប់ការពិត មិនអៀនខ្មាស់ដូចមុន។ នាងបានជាសះស្បើយពីជំងឺ ហើយបានទៅ រៀនទៀងទាត់ឡើងវិញ។ លោក **លន់ ស៊ីថូ** ជានាយកសាលាបឋមសិក្សាទួលរកា បាន មានប្រសាសន៍ថា “**ខ្ញុំពិតជារីករាយណាស់! វាប្លែកសម្រាប់សាលារបស់ខ្ញុំ ព្រោះពីមុនមក មិនដែលមានកម្មវិធីនេះទេ ហើយសាលាក៏ មិនធ្លាប់ធ្វើសកម្មភាពជាមួយកុមារីបែបនេះពី មុនមកដែរ។ ប៉ុន្តែគម្រោងបានឈ្មុសឈ្មុល ទាក់ទងសួររកម្តាយ រក្សា ដោយផ្តល់ការគាំទ្រ ជាថ្លៃធ្វើដំណើរ និងព្យាបាល ហើយបើ គម្រោងធ្វើរបៀបនេះដល់កុមារីជាច្រើនទៀត នោះកាន់តែល្អ។ ខ្ញុំឃើញរក្សារៀនសូត្រ ក្លាហាន និងមានសុខភាពល្អជាងមុន** ”។

បច្ចុប្បន្ននេះ រក្សាមានភាពសប្បាយរីករាយ លទ្ធផលសិក្សាមានភាពប្រសើរវិញ និងចូលរួមសកម្មភាពផ្សេងៗជាមួយមិត្តភក្តិ នៅថ្នាក់រៀន ជាពិសេសចេះពិភាក្សាជាមួយ ឪពុកម្តាយអំពីសុខភាពផ្ទាល់ខ្លួន។ កំពុង អង្គុយដោយទឹកមុខមានក្តីសង្ឃឹមលើកៅអី មុខផ្ទះពូរបស់នាង រក្សាបាននិយាយថា “**ឥឡូវនេះ នាងខ្ញុំបានធូរច្រើន និងសប្បាយ ចិត្តខ្លាំងព្រោះមានអ្នកគ្រូប្រឹក្សាកុមារីជួយផ្តល់ កំលាំងចិត្ត។ នៅថ្ងៃអនាគត ខ្ញុំចង់ក្លាយទៅជា នគរបាលម្នាក់។ ខ្ញុំនឹងខិតខំប្រឹងប្រែងរៀន សូត្រឱ្យបានពូកែ** ”។

គម្រោង E2L ផ្តល់ឱ្យរក្សានូវកង់ សម្ភារសិក្សា របស់ប្រើប្រាស់ផ្ទាល់ខ្លួន (សាឡីអនាម័យសម្រាប់ការពារពេលមករដូវ និងសាប៊ូដុសដៃជើង) ដល់រក្សា និងបង្កើតសកម្មភាព ត្រួតពិនិត្យតាមដាន។ល។ អ្នកស្រី ស្រីមៅ បានមានប្រសាសន៍ថា “**ប្រសិនបើគ្មានអ្នកគ្រូ ប្រឹក្សាកុមារីខាងគម្រោងចុះមកជួយដល់កូន របស់ខ្ញុំទេ ម្លោះកូនរបស់នាងខ្ញុំមិនបានផ្លាស់ ប្តូរល្អប្រសើរដូចបច្ចុប្បន្ននេះទេ** ”។

អង្គការ ខេប សម្រេចបានជោគជ័យជា ច្រើនលើការប្រតិបត្តិគម្រោងអប់រំដល់កុមារ និងយុវជនរយៈពេលជាង២០ឆ្នាំកន្លងមក នេះ។ អង្គការបានជួយបន្តពង្រឹងគុណភាព គ្រូ និងនាយកសាលាក្នុងការបង្រៀនការគ្រប់ គ្រងសាលា កម្មវិធីអប់រំបរិយាបន្នសម្រាប់ កុមារ និងយុវជននៅក្នុងវិស័យអប់រំ។ អង្គការ ខេប នៅតែបន្តស្វែងរកដៃគូអភិវឌ្ឍន៍ផ្សេងៗ ដែលអាចឆ្លើយតបនឹងតម្រូវការយុវជន និង កុមារដែលងាយរងគ្រោះ។ អង្គការ ខេប បាន ធ្វើការងារជាមួយអង្គការឆាលហ្វានកម្ពុជា និងដៃគូចម្រុះដទៃទៀត រួមមាន៖ ក្រសួង អប់រំ យុវជន និងកីឡា រដ្ឋាភិបាលថ្នាក់ក្រោម ជាតិ សាលារៀន សហគមន៍ អង្គការមិនមែរ ដ្ឋាភិបាល និងអ្នកពាក់ព័ន្ធជាច្រើនទៀត។ កុមារី រក្សា ត្រូវការបន្តលើកទឹកចិត្តទាំងកំ លាំងកាយ និងស្មារតីឱ្យគាត់បានសប្បាយ ចិត្តខំរៀន មានដំណោះស្រាយបញ្ហាសុខ ភាព និងមានសេចក្តីសង្ឃឹមនៅក្នុងជីវិត៕

# ហេតុអ្វីយុវជនត្រូវយល់ដឹងពីយុគសម័យឌីជីថល ?



កាលណាប្រទេសជាតិមួយមានធនធានយុវជនដែលប្រកបដោយការអប់រំខ្ពស់ ភាពឈ្លាសវៃ មានការសាមគ្គីគ្នាជាធ្លុងមួយ ចូលរួមអភិវឌ្ឍប្រទេសជាតិដើម្បីធ្វើឲប្រទេសមួយជឿនលឿនទៅមុខ ដើរទាន់មាគ៌ាអភិវឌ្ឍ។

លោក ធី ដាលីន ជាគ្រូបង្គោលអក្ខរកម្មឌីជីថលអាស៊ាន និងជាគ្រូបង្រៀននៅវិទ្យាល័យបរកែវ ខេត្តរតនគិរី។ លោកបានចូលរួមកម្មវិធីអក្ខរកម្មឌីជីថលអាស៊ានតាំងពីខែធ្នូ ឆ្នាំ២០២២មក ដោយសារលោកចង់ពង្រឹងចំណេះដឹងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗឱ្យបានសមស្រប។ នៅពេលបច្ចុប្បន្ននេះ មនុស្សរស់នៅក្នុងសម័យឌីជីថល ហើយអាចស្វែងរកព័ត៌មានគ្រប់ប្រភេទពីច្រើនប្រភពបាននៅលើប្រព័ន្ធអនឡាញ យ៉ាងងាយស្រួល និងលឿនបំផុតតាមរយៈស្មាតហ្វូន (ទូរសព្ទឆ្លាតវៃ) SmartWatch, iPad, Tablet, កុំព្យូទ័រយួរដៃ (Laptop) កុំព្យូទ័រ Desktop និងឧបករណ៍ដទៃទៀត។ ក្នុងសម័យឌីជីថលដ៏សម្បូរបែបនេះ ក៏មានជនខិលខូច ឬ Hacker មួយចំនួនកំពុងរិះរកល្បិចកលដើម្បីឆ្លៀតឱកាសកេងបន្លំ និងបោកប្រាស់ ប្រសិនបើយើងចុចលើតំណភ្ជាប់ (Link) ឬសន្ទនាជាមួយមនុស្សដែលយើងមិនស្គាល់ប្រភពច្បាស់លាស់នោះទេ យើងអាចក្លាយជាជនងាយរងគ្រោះតាមបណ្ដាញសង្គមនានា។

នៅមុនពេលចូលរួមក្នុងកម្មវិធីឌីជីថលអាស៊ាននេះ លោក ដាលីន មិនសូវយល់ដឹងច្រើនទេពាក់ព័ន្ធនឹងអក្ខរកម្មឌីជីថល ហើយក៏មិនបានចែករំលែកចំណេះដឹងទៅដល់សិស្សដែរ ដោយសារចំណេះដឹងរបស់លោកនៅមានកម្រិត ហើយលោកមិនយល់ច្បាស់អំពីការបែងចែកព័ត៌មានពិត និងព័ត៌មានមិនពិត ពីព្រោះលោកក៏ធ្លាប់ចាញ់បោកព័ត៌មានដែរ។ នៅវេលាថ្ងៃមួយនោះ លោកបានចែករំលែកព័ត៌មានមួយ ក្រោយមកទើបដឹងថាព័ត៌មាននោះមិនពិត។ ចំណែសិស្សរបស់លោកភាគច្រើនមិនសូវបានយល់ដឹងពីការចែករំលែកព័ត៌មាននៅលើបណ្ដាញសង្គមនោះទេ ពួកគាត់ចូលចិត្តចែករំលែកព័ត៌មានតាមគ្នាដោយមិនបានគិតវែងឆ្ងាយទៅថ្ងៃមុខ។ លោក ដាលីន មានការព្រួយបារម្ភច្រើនចំពោះសិស្សរបស់គាត់ ដែលអាចនឹងចាញ់បោកជនអនាមិក ប្រសិនបើពួកគាត់មិនមានការយល់ដឹងគ្រប់គ្រាន់លើការចែកចាយព័ត៌មាននេះ។

ក្រោយពេលទទួលបានវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន គ្រូបង្គោលទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយទៅដល់សហគមន៍របស់ខ្លួន។ លោក ដាលីន ទទួលបានចំណេះដឹងជាច្រើនអំពីអក្ខរកម្មឌីជីថល រួមមាន៖ ការអានបែបវិភាគ ឥទ្ធិពលព័ត៌មាន យុគសម័យព័ត៌មានមិនពិត សុវត្ថិភាពអនឡាញមូលដ្ឋាននៃឯកជនភាព និងសន្តិសុខតាមប្រព័ន្ធអុីនធើណែត ប្រវត្តិឌីជីថល ដានជើងឌីជីថល អត្តសញ្ញាណឌីជីថល តុល្យភាពនៃប្រព័ន្ធផ្សព្វផ្សាយ និងសុខុមាលភាពក្នុងការប្រើប្រាស់។ ម្យ៉ាងវិញទៀត លោកបានយល់ច្បាស់លើការកត់សម្គាល់ព័ត៌មានពិត គឺជាព័ត៌មានដែលបានផ្សាយចេញពីស្ថាប័នមួច្បាស់លាស់មានប្រភពត្រឹមត្រូវ ដូចជា ព័ត៌មានផ្សាយចេញពីស្ថានប័នក្រសួង និងស្ថានប័នសារព័ត៌មាន (ស៊ីធីអិន ហង្សមាស)។ ព័ត៌មានទាំងអស់នោះជាព័ត៌មានពិត អាចជឿកជាក់បាន ទើបគេផ្សាយចេញមកជាសាធារណៈ ហើយចំពោះ

សូមអានបន្តទំព័រ២២...

តពីទំព័រ២១... ព័ត៌មានមិនពិតវិញ ជាព័ត៌មានមិនមានប្រភពច្បាស់លាស់ផ្សាយចេញមកក្នុងចេតនាមិនល្អដើម្បីបំពុលសង្គម។

បច្ចុប្បន្ននេះ មានព័ត៌មានជាច្រើនបានផ្សព្វផ្សាយនៅតាមប្រព័ន្ធបណ្ដាញសង្គម ប្រសិនបើយុវជនមិនចេះកំណត់ប្រភព និងបែងចែកអ្វីជាព័ត៌មានពិត និងមិនពិតទេនោះ ពួកគាត់នឹងងាយចាញ់បោកគេនៅតាមវេទិកាអនឡាញទាំងអស់នោះជាមិនខាន។ ដូច្នេះ ការប្រុងប្រយ័ត្នក្នុងការចែករំលែកព័ត៌មានទៅកាន់មនុស្សជុំវិញខ្លួនគឺជារឿងសំខាន់។

ក្នុងចំណោមប្រធានបទជាច្រើន លោក ដាលីន បានជ្រើសរើសពីរប្រធានបទក្នុងការចែករំលែកទៅកាន់សិស្ស គឺយុគសម័យព័ត៌មានមិនពិត និងដានជើងឌីជីថល។ លោកយល់ឃើញថាសិស្សវិទ្យាល័យជាសិស្សវ័យជំទង់ ហើយពួកគាត់ពិតជាធនធានយុវជនដែលចាំបាច់ត្រូវតែមានចំណេះដឹងផ្នែកឌីជីថល ពីព្រោះវាមានសារៈសំខាន់ណាស់សម្រាប់ការសិក្សា និងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ក្នុងការទទួលបានព័ត៌មានពីប្រព័ន្ធអនឡាញ។ ដូច្នេះ គាត់ជឿជាក់យ៉ាងមុតមាំថា សិស្សនឹងយកវាទៅប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ និងបន្តចែករំលែកទៅកាន់ក្រុមគ្រួសារ មិត្តភក្តិ និងមនុស្សជុំវិញខ្លួន ដែលជាការដាស់តឿន និងពង្រឹងស្មារតី កុំឱ្យងាយចាញ់បោកជនខិលខូច។

កម្មវិធីអក្ខរកម្មឌីជីថលអាស៊ានពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ធនធានចំណេះដឹងផ្នែកបច្ចេកវិទ្យាដល់សង្គម ជាពិសេសយុវជនផ្ទាល់តែម្ដងឱ្យចេះការពារឯកជនភាពរបស់ខ្លួនឱ្យមានសុវត្ថិភាពខ្ពស់។ លោក ដាលីន បានមានប្រសាសន៍ថា "បើទោះបីជាកម្មវិធីឌីជីថលអាស៊ានមានរយៈពេលខ្លីក៏ដោយ ខ្ញុំនៅតែបន្តចែករំលែកចំណេះដឹងទៅកាន់សិស្សរបស់ខ្ញុំឱ្យចេះប្រុងប្រយ័ត្នក្នុងការចែករំលែកព័ត៌មានអ្វីមួយនៅតាមបណ្ដាញសង្គម។ ខ្ញុំពិតជាចង់ឱ្យកម្មវិធីឌីជីថលអាស៊ាននេះនៅតែបន្តសកម្មភាព ដើម្បីចែករំលែកទៅកាន់សហគមន៍ផ្សេងៗទៀត ជាពិសេសតំបន់ដាច់ស្រយាល"។

ក្រោមជំនួយហិរញ្ញប្បទានពីមូលនិធិអាស៊ាន អង្គការ ខេប បានប្រតិបត្តិកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន ដោយបានធ្វើការជ្រើសរើសគ្រូឧទ្ទេសចំនួន៨៥នាក់ ដើម្បីទទួលវគ្គបណ្ដុះបណ្ដាលធ្វើជាគ្រូបង្គោលផ្នែកអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានសម្រាប់បង្រៀនដល់សហគមន៍ គ្រូបង្រៀន អ្នកអប់រំ ថ្នាក់ដឹកនាំក្នុងសហគមន៍ មន្ត្រីរដ្ឋាភិបាល និងមនុស្សចាស់។

ក្រៅពីកម្មវិធីឌីជីថលអាស៊ាន អង្គការ ខេប មានគម្រោង និងកម្មវិធីជាច្រើនទៀត ដែលកំពុងចូលជួយអន្តរាគមន៍នៅតាមសាលារៀនរដ្ឋគោលដៅនៅទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុងការលើកកម្ពស់ការអប់រំកុមារ និងយុវជនប្រកបដោយវឌ្ឍនភាពខ្ពស់៕



# កម្មវិធីត្រីវិស័យជួយគ្រូបង្រៀន និងដឹកនាំសិស្សបង្កើតទិសដៅជីវិត



សិស្សកំពុងពន្យល់មិត្តភក្រអំឡុងពេលធ្វើលំហាត់ការងារក្រុម អំពីការកំណត់គោលបំណងនៅក្នុងការសិក្សា និងជីវិតទៅថ្ងៃអនាគត។

អ្នកគ្រូ កៅ សុខ ជានាយិការង និងបានទទួលបន្ទុកបង្រៀនកម្មវិធីត្រីវិស័យរបស់គម្រោង CO-SAVED នៅអនុវិទ្យាល័យភ្នំលក ដែលជាសាលាគោលដៅស្ថិតក្នុងតំបន់ជនបទ និងមានចម្ងាយប្រមាណជាង ៣៨ គីឡូម៉ែត្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត។ អ្នកគ្រូ សុខ មានភាពសប្បាយរីករាយខ្លាំងក្រោយឃើញសិស្សរបស់គាត់ មានការផ្លាស់ប្តូរឥរិយាបទ ចេះរៀបចំធ្វើផែនការ និងកំណត់ទិសដៅទិសដៅក្នុងការសិក្សារបស់ពួកគេ។ អ្នកគ្រូមិនសូវបារម្ភខ្លាំងដូចមុនលើការសិក្សាសិស្ស ជាពិសេសការគ្រប់គ្រងសាលា និងដឹកនាំសិស្សសិក្សា។ អនុវិទ្យាល័យភ្នំលកមានសិស្សចំនួនជាង ៣០០នាក់ ជាកូនអ្នកនេសាទនៅតាមឆ្នេរសមុទ្រ។

មុនពេលមិនទាន់មានគម្រោង CO-SAVED ចូលមក អ្នកគ្រូ សុខ បារម្ភច្រើនលើការសិក្សាសិស្ស ព្រោះសិស្សទាំងនោះមកសិក្សាឱ្យតែបានៗតែប៉ុណ្ណោះ មិនទៀងទាត់ពេលវេលា ដោយមិនទាន់យល់ដឹងថាអ្វីទៅជាការធ្វើផែនការ និងកំណត់ទិសដៅការសិក្សា ការយល់ដឹងអំពីការស្វែងរកសាកលវិទ្យាល័យសិក្សាបន្ត ការជ្រើសរើសជំនាញ និងសិស្សខ្លះមានលទ្ធភាព ប៉ុន្តែពួកគេមិនដឹងថាតើកំណត់អនាគតបែបណា។ ម្យ៉ាងវិញទៀត សិស្សដែលគ្មានទូរសព្ទប្រើប្រាស់មួយចំនួនតូចដែលអត់យល់នោះ ក៏មានការលំបាកច្រើន និងបាក់ទឹកចិត្តផងដែរ ហើយមិនមានការតាមដានការសិក្សាពួកគាត់បានសុក្រឹតច្រើននោះទេ។ ឪពុកម្តាយសិស្សភាគច្រើនជាប្រជាជនប្រកបមុខរបរនេសាទ និងរស់នៅតាមតំបន់ឆ្នេរសមុទ្រ គ្មានពេលវេលាច្រើនសម្រាប់តាមដានអំពីការសិក្សាកូន គ្មានកម្មវិធីងាយស្រួលផ្តល់ព័ត៌មានដល់ពួកគាត់។ សិស្សសាលាអ្នកគ្រូប្រឈមនឹងការឈប់រៀនច្រើន ដោយសារសិស្សត្រូវបានទាក់ទាញទៅសិក្សាភាសាចិន ព្រោះងាយឆាប់ចេញរកងារធ្វើទទួលបានប្រាក់ខែខ្ពស់។ សិស្សនៅវិទ្យាល័យភ្នំលកនេះមិនបានជ្រួលជ្រើមស្វែងយល់អំពីចំណេះដឹងបន្ថែមដែលទាក់ទងនឹងជីវិតជាក់ស្តែង និងសម្បូរអវត្តមាន។ ពួកគាត់ផ្អាកសិក្សាដើម្បីទៅជួយលើកឈើបនៅក្នុងសមុទ្រជាមួយឪពុកម្តាយ។ សូមអានតទំព័រ២៤...



អ្នកគ្រូ កែវ សុខ បានបង្រៀនកម្មវិធីត្រីវិស័យដល់សិស្សរបស់គាត់ និងហៅសិស្សស្ម័គ្រចិត្តចែករំលែកអំពីអ្វីដែលពួកគេបានសិក្សាតាមកម្មវិធីត្រីវិស័យនេះមកបង្ហាញដល់មិត្តភក្រនៅក្នុងថ្នាក់រៀន។




តពីទំព័រ២៣... បន្ទាប់ពីមានគម្រោង CO-SAVED របស់អង្គការ ខេប បានដាក់បញ្ចូលកម្មវិធីត្រីវិស័យនៅអនុវិទ្យាល័យភ្នំលកឱ្យសិស្សសិក្សាមក សិស្សរបស់អ្នកគ្រូចំនួនជាង ៨០% ដឹងច្បាស់ ថាតើពួកគេត្រូវសិក្សាបែបណា? ធ្វើអ្វី? ជ្រើសរើសអ្វីទៅថ្ងៃអនាគត? កម្មវិធីត្រីវិស័យនេះមានលក្ខណៈទូលំទូលាយ។ សិស្សមានការផ្លាស់ប្តូរច្រើន ជាពិសេសតាមរយៈការសិក្សាកម្មវិធីត្រីវិស័យ (Trey Visay App)។ ពួកគាត់មានភាពជ្រួលជ្រើមចង់ដឹងអំពីជំនាញ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជាច្រើនដែលត្រូវជ្រើសរើសក្រោយបញ្ចប់ការសិក្សានៅមធ្យមសិក្សា ជាពិសេសការស្រាវជ្រាវរកប្រភពព័ត៌មានច្បាស់លាស់ និងមានភាពលឿនរហ័ស។ លោកគ្រូអ្នកគ្រូមានវិធីសាស្ត្រថ្មីល្អៗសម្រាប់តាមដានការសិក្សា និងវត្តមានរបស់សិស្ស។ អ្នកគ្រូ សុខ បង្រៀនកម្មវិធីត្រីវិស័យនេះដល់សិស្សដោយប្រើប្រាស់ទូរសព្ទដៃប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលបច្ចុប្បន្ននេះ ក៏អ្នកគ្រូ សុខ មិនបានភ្លេចការបារម្ភចំពោះសិស្សរបស់គាត់ដែលទទួលបានការជំរុញទឹកចិត្តទៅរៀនភាសាចិនច្រើនជាងមកសិក្សាសាលាខ្មែរនោះដែរ។

កំពុងអង្គុយធ្វើការនៅក្នុងការិយាល័យ អ្នកគ្រូ សុខ បានមានប្រសាសន៍ថា "ការចូលរួមពីគម្រោង CO-SAVED បានជំរុញលើកទឹកចិត្តទាំងគ្រូ និងសិស្សនៅសាលារៀនរបស់នាងខ្ញុំពង្រឹងការតាមដានសិស្ស ហើយសិស្សសិក្សាបានលទ្ធផលល្អប្រសើរច្រើន។ ទោះបីសិស្សនាងខ្ញុំចង់ទៅរៀនភាសាចិន ដើម្បីរកការងារបានប្រាក់ចំណូលបានរាប់រយដុល្លារក៏ដោយ ក៏ខ្ញុំនៅតែពន្យល់បង្ហាញសិស្សខ្ញុំកុំឱ្យបាក់ទឹកចិត្តឈប់រៀន។ នាងខ្ញុំបានលើកយកឧទាហរណ៍អំពីអ្នកដែលមានជំនាញពិតមិនខ្វះការងារល្អធ្វើ។ កម្មវិធីត្រីវិស័យបានធ្វើឱ្យសិស្សនាងខ្ញុំពុះកញ្ជ្រោលចង់ចេះ ចង់ដឹងច្រើនអំពីរបៀបជ្រើសរើសជំនាញឱ្យត្រូវនឹងចំណូលចិត្ត។ ម្យ៉ាងវិញទៀត លោកគ្រូអ្នកគ្រូ និងនាងខ្ញុំព្យាយាមធ្វើយ៉ាងណា ជាពិសេសបរិស្ថានសាលារៀន ដើម្បីឱ្យសិស្សមកសិក្សាមានភាពសប្បាយរីករាយជាងនៅផ្ទះ "។

នៅពេលមានអវត្តមានសិស្សច្រើន អ្នកគ្រូនិងសហការីគាត់បានចុះទៅសួរសុខទុក្ខផ្ទាល់តាមផ្ទះសិស្សដោយទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន និងឪពុកម្តាយផ្ទាល់ដើម្បីទទួលយោបល់ និងមើលអំពីបញ្ហាជាក់ស្តែង។ ក្រៅពីកម្មវិធីត្រីវិស័យ ក៏មានប្រព័ន្ធរំលឹកទុកជាមុន ឬការទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្សបានជួយអ្នកគ្រូពង្រឹងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល និងប្រជុំជាមួយអ្នកបច្ចេកទេសគម្រោង។

គម្រោងបានផ្តល់ជាកញ្ចប់សម្ភារៈអាហារូបករណ៍ដល់សិស្សក្រីក្រ ដែលជាសកម្មភាពជួយកាត់បន្ថយបន្ទុកលំបាករបស់គណៈគ្រប់គ្រងសាលារៀនផងដែរ។ អ្វីដែលធ្វើឱ្យអ្នកគ្រូ សុខ ផ្លាស់ប្តូរការគ្រប់គ្រងបង្រៀន និងដឹកនាំសិស្ស គឺការជួបជាមួយនាយក និងគ្រូបង្រៀនមកពីសាលារៀនផ្សេងៗធ្វើការផ្លាស់ប្តូរបទពិសោធន៍គ្នា និងវិធីសាស្ត្រដោះស្រាយបញ្ហាប្រឈមទៅវិញទៅមកក្នុងពេលមានវគ្គបណ្តុះបណ្តាល។

លោក **សុខ ទី** នាយកអនុវិទ្យាល័យភ្នំលក បានមានប្រសាសន៍ថា **"ខ្ញុំមើលឃើញថា អ្នកគ្រូ កៅ សុខ ដឹងអំពីវិធីដឹកនាំសិស្សល្អច្រើនជាងមុន ទោះបីអ្នកគ្រូត្រូវទទួលបន្ទុកការងារបង្រៀនកម្មវិធីត្រីវិស័យបន្ថែមក៏ដោយ។ គាត់ទទួលបានវគ្គបំប៉នសមត្ថភាពពីគម្រោងធ្វើឱ្យការងារគាត់ប្រសើរជាងមុន។ សិស្សរបស់ខ្ញុំស្ទើរទាំងអស់ទទួលបានការសិក្សាកម្មវិធីត្រីវិស័យ ដែលបានធ្វើឱ្យពួកគាត់ចេះកំណត់ទិសដៅតាមរយៈទូរសព្ទដៃ "**។

គម្រោង CO-SAVED ត្រូវបានប្រតិបត្តិដោយអង្គការ ខេប ដោយសហការជាមួយអង្គការ Aide et Action (អេដ អេ អាក់ស្យុង)(AeA) ក្រោមជំនួយហិរញ្ញប្បទានសហភាពអឺរ៉ុប។ គម្រោង CO-SAVED បានផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀន នាយកសាលា បណ្ណារក្ស ការប្រជុំឪពុកម្តាយ គណៈកម្មការគ្រប់គ្រងសាលារៀន ប្រព័ន្ធរំលឹកទុកជាមុន សម្ភារៈអាហារូបករណ៍ ជួសជុលអគារសិក្សា បណ្ណាល័យ ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់សាលាមត្តេយ្យសហគមន៍ ជួសជុលនិងកសាងបង្គន់អនាម័យ ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់សិស្សកូនអ្នកនេសាទនៅក្នុងគម្រោង ដោយធ្វើសកម្មភាពសំខាន់ៗបង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងគុណភាពសិក្សារបស់កុមារថ្នាក់បឋម និងមធ្យមសិក្សានៅក្នុងតំបន់ និងបង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងគុណភាពសិក្សាសម្រាប់សិស្សអនុវិទ្យាល័យនៅក្នុងតំបន់គម្រោង CO-SAVED។ កម្មវិធីត្រីវិស័យបានជួយច្រើនដល់សិស្សនៅអនុវិទ្យាល័យភ្នំលក ឱ្យខិតខំខ្នះខ្នែងសិក្សារហូតដល់ទទួលបានលទ្ធផលល្អប្រសើរជាងមុខ ជាពិសេសផ្តល់វិធីសាស្ត្រដល់លោកគ្រូអ្នកគ្រូសម្រាប់តាមដានការសិក្សា និងវត្តមានរបស់សិស្សផងដែរ៕

# ថវិកាបជិភាគពន្លឿនដំណើរការរអភិវឌ្ឍន៍សាលារៀន

សាលាបឋមសិក្សា កោះគ្រឹស្នា គឺជាសាលារៀនមួយក្នុងចំណោមសាលារៀនគោលដៅរបស់គម្រោងCO-SAVED ស្ថិតនៅក្នុងស្រុកកំពង់ត្រាច មានចម្ងាយ៣៧,៥គីឡូម៉ែត្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត។ សាលានេះមានអគារសិក្សាចំនួន១ខ្នង ស្មើ៦បន្ទប់ មានគ្រូបង្រៀនចំនួន៦នាក់ និងសិស្សចំនួន១៣០នាក់ ដែលជាកូនរបស់អ្នកនេសាទនៅតាមឆ្នេរសមុទ្រ។ លោកស្រី ទន់ សុគន្ធា ជានាយិកា និងជាគ្រូបង្រៀននៅសាលាបឋមសិក្សា កោះគ្រឹស្នា មានសេចក្តីសប្បាយចិត្តខ្លាំងចំពោះសមិទ្ធិផលអភិវឌ្ឍន៍សាលារៀន ជាពិសេសការកើនឡើងសមត្ថភាពរបស់នាយិកា គ្រូបង្រៀន បណ្ណារក្ស និងគណៈកម្មការគ្រប់គ្រងសាលារៀនក្រោយទទួលបានវគ្គបណ្តុះបណ្តាលពីគម្រោង។



អ្នកគ្រូ ទន់ សុគន្ធា កំពុងអាន និងពន្យល់អំពីគោលបំណងនៃលំហាត់ឱ្យសិស្សធ្វើមុខវិជ្ជាភាសាខ្មែរ។

មុនពេលមិនទាន់មានគម្រោង CO-SAVED ចូលមកអន្តរាគមន៍ សាលាបឋមសិក្សា កោះគ្រឹស្នា មានការខ្វះខាតច្រើន រួមមាន៖ បរិស្ថានសាលាមិនស្អាត ខ្វះខាតសម្ភារៈសម្រាប់បង្រៀន និងរៀន។ លោកគ្រូអ្នកគ្រូត្រូវប្រើប្រាស់ការច្នៃប្រឌិតដោយខ្លួនឯង មានជាក្រដាសយកមកគូរវាស ប៉ុន្តែសម្ភារៈទាំងនោះប្រើប្រាស់មិនបានយូរ ឆាប់ខូច និងចំណាយបន្ថែមច្រើន។ ការបង្រៀន និងដឹកនាំសាលាត្រូវបានអនុវត្តតាមបែបប្រពៃណី គ្មានប្រព័ន្ធតាមដានការសិក្សា ឬទប់ស្កាត់ការបោះបង់ការសិក្សា គ្មានកន្លែងអនាម័យលាងដៃសម្រាប់កុមារ ថ្នាក់រៀនគ្មានភាពទាក់ទាញ ឬរៀបចំតាមសាលាកុមារមេត្រីត្រឹមត្រូវល្អឡើយ។ ការកៀរគររកថវិកាពីសហគមន៍នៅមានកម្រិត ព្រោះគណៈកម្មការគ្រប់គ្រងសាលាមិនទាន់យល់ដឹងអំពីតួនាទីភារកិច្ចរបស់ខ្លួនបានច្បាស់លាស់។ ចំណែកការការផ្សព្វផ្សាយព័ត៌មានសិក្សារបស់កុមារទៅកាន់ឪពុកម្តាយសិស្ស និងពីសិស្សមកកាន់សាលាវិញគ្មានលក្ខណៈទូលំទូលាយនោះទេ។ ពេលកុមារចេញលេងម្តងៗមានការលំបាករកកន្លែងរត់លេង ដោយសារបរិស្ថានសាលារៀនមិនមានការរៀបចំស្អាតល្អ ខ្វះសួនច្បារលម្អ គ្មានសួនជីវៈ និងសួនកុមារ។ កត្តាលំបាកទាំងនេះបានជំរុញនាយិកាស្វះស្វែងរកគ្រប់មធ្យោបាយដើម្បីរកជំនួយឧបត្ថម្ភគាំទ្រពីខាងក្រៅ។

បន្ទាប់ពីគម្រោងCO-SAVED របស់អង្គការ ខេប បានចូលមកអន្តរាគមន៍នៅសាលាបឋមសិក្សា កោះគ្រឹស្នា នេះអស់រយៈពេល២ឆ្នាំកន្លងមក **សូមអានបន្តទំព័រ២៦...**



អ្នកគ្រូ ទន់ សុគន្ធា ឈរជាមួយសិស្សដែលជាក្រុមប្រឹក្សាកុមារនៅក្នុងបរិវេណមុខសាលារៀនប្រកបដោយស្នាមញញឹម។

**តពីទំព័រ២៥...** បានធ្វើឱ្យសាលារៀននេះមានការផ្លាស់ប្តូរមុខមាត់ថ្មី និងរីកចម្រើនច្រើន។ ការមានទំនាក់ទំនង និងភាពជាអ្នកដឹកនាំសាលាល្អជាពិសេសជាមួយការិយាល័យអប់រំ យុវជន និងកីឡាស្រុក ទាក់ទាញបានដៃគូអភិវឌ្ឍន៍គឺអង្គការ ខេប តាមរយៈគម្រោង CO-SAVED ដែលនាំមកនូវជំនួយបច្ចេកទេស និងថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀនចាប់តាំងពីឆ្នាំ២០២១មក។

គម្រោងនេះបានជួយកែលម្អបរិស្ថានសាលារៀន ការតុបតែងថ្នាក់ សម្ភារៈបង្រៀនរបស់គ្រូ កែលម្អកន្លែងអនាម័យលាងដៃ ជាពិសេសវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្រៀនសិស្សរៀនយឺត និងសិស្សប្រឈមនឹងការបោះបង់ការសិក្សា។

ការជួយបំប៉នដល់សិស្សរៀនយឺត និងសិស្សធ្លាក់មធ្យមភាគគឺពិតជាសកម្មភាពដ៏ល្អរបស់គម្រោងដែលបានលើកទឹកចិត្តពួកគេមិនឱ្យបោះបង់ការសិក្សាបានរីករាយជាមួយគ្រូ និងថ្នាក់រៀនតុបតែងស្អាត។ មធ្យមភាគរបស់សិស្សទាំងនោះកើនល្អជាងមុនបើប្រៀបធៀបពេលគម្រោងមិនទាន់មកដល់ ដោយបច្ចុប្បន្ននេះ ពួកគាត់អាចបន្តឡើងថ្នាក់បាន។ នៅក្នុងឆ្នាំ២០២៣សាលាបឋមសិក្សា កោះគ្រឹស្នា ទទួលបានថវិកាអភិវឌ្ឍន៍សាលារៀនចំនួន២ ៨០០ ០០០ រៀល ពីគម្រោងបូកថវិការបស់សាលាចំនួន ២ ៦៥០ ០០០រៀល សម្រាប់កែលម្អបរិស្ថាន ការតុបតែងថ្នាក់រៀនតាមកម្មវិធីសាលាកុមារមេត្រី និងការផលិតសម្ភារៈបង្រៀនតាមមុខវិជ្ជានីមួយៗ។ គម្រោងក៏បានជួយបណ្តុះបណ្តាលដល់គណៈកម្មការគ្រប់គ្រងសាលា នាយក និងក្រុមប្រឹក្សាកុមារបន្ថែមទៀតផង។

អ្នកគ្រូ **ទន់ សុគន្ធា** បានមានប្រសាសន៍ថា "**នាងខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ ដោយបានគម្រោងរបស់អង្គការ ខេប ចូលរួមមានទាំងថវិកាបដិភាគជាមួយសាលា និងបានធ្វើឱ្យការងារអនុវត្តក្នុងសាលាទទួលបានជោគជ័យច្រើន ហើយយើងមានគម្រោងតុបតែងទីចាត់ការសាលា ចាក់ដីធ្វើសួនជីវៈចម្រុះ និងសួនកុមារនៅឆ្នាំក្រោយ។ ដើម្បីឱ្យកុមារចូលចិត្តមកសាលារៀនពេញលេញ គឺតម្រូវឱ្យគ្រូបង្រៀនមកបង្រៀនទៀងទាត់ គោរពម៉ោងចេញចូល ជាពិសេសគ្រូត្រូវមានសម្ភារៈបង្រៀនទាក់ទាញ។ ចំណែកបន្ទប់រៀនវិញ គ្រូត្រូវរៀបចំឱ្យមានសណ្តាប់ធ្នាប់ មានសោភណ្ឌភាព ជាបន្ទប់ កុមារមេត្រី ការលើកទឹកចិត្តរបស់គ្រូជាមួយសិស្ស។ នាងខ្ញុំសំណូមពរឱ្យអង្គការ ខេប បំប៉នសមត្ថភាពគ្រូបង្រៀននូវជំនាញថ្មីៗបន្ថែមទៀត**"។


បរិវេណសាលារៀនស្អាតគឺជាចំណុចទាក់ទាញសិស្សនៅពេលពួកគេឈានជើងចូលសាលាដំបូង ជាពិសេសប្រព័ន្ធទឹកស្អាតដែលជួយជំរុញសាលាឱ្យមានដំណើរការល្អសម្រាប់អប់រំកុមារ។

ទោះបីមានការចូលរួមអភិវឌ្ឍសាលារៀនក្នុងរយៈពេលខ្លីក្តី ក៏គម្រោង CO-SAVED ពិតជាបាននាំមកនូវការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន និងរៀន បរិស្ថានសាលា ការរៀបចំថ្នាក់រៀន កន្លែងអនាម័យលាងដៃ និងផ្នែកផ្សេងៗជាច្រើនទៀតនៅសាលាបឋមសិក្សា កោះគ្រឹស្នា ដែលបានឆ្លើយតបនឹងតម្រូវការរបស់កុមារជាក់ស្តែងនៅក្នុងមូលដ្ឋាន។ លោកគ្រូអ្នកគ្រូទទួលបានបទពិសោធន៍ និងចំណេះដឹងនៅក្នុងការប្រតិបត្តិគម្រោង CO-SAVED។

នៅពេលដល់ម៉ោងចេញលេងភ្លាម លោក **កង វិត** ដែលជាគ្រូបង្រៀនថ្នាក់ទី៦ បានមានប្រសាសន៍ថា "**គម្រោង CO-SAVED បានធ្វើឱ្យសាលារៀនខ្ញុំរីកចម្រើនច្រើន ដូចជា ការតុបតែងថ្នាក់ ការបំប៉នសិស្សរៀនយឺត និងការកែលម្អផ្នែកបរិស្ថានសាលារៀន។ ក្រៅពីនេះ គម្រោងបានផ្តល់ជាវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធរំឭកជាមុន ការដើរបង្រៀនកុមារតាមភូមិ និងការតាមដានគ្រូបង្រៀនសិស្សតាមខ្នងផ្ទះ។ គម្រោងនេះបានជួយឱ្យសាលារៀនខ្ញុំល្អហើយ តែខ្ញុំសូមឱ្យគម្រោងបន្តទៅជួយសាលារៀងផ្សេងទៀត**"។

សិស្សឈ្មោះ **ម៉េងជូ** ប្រធានក្រុមប្រឹក្សាកុមារ និងជាសិស្សថ្នាក់ទី៥ បាននិយាយថា "**ខ្ញុំសប្បាយចិត្តណាស់ ព្រោះនៅក្នុងថ្នាក់រៀនខ្ញុំមានការតុបតែងល្អ ដូចជា ស្រះនិស្ស័យ ព្យញ្ជនៈ គ្មានសម្រាម មានសណ្តាប់ធ្នាប់ល្អ និងមុខថ្នាក់មានសួនផ្កាស្អាត។ ឥឡូវបរិវេណសាលាស្អាត មានស្មៅ កន្លែងដាក់កង់មានរបៀបល្អ ហើយអ្នកគ្រូបង្រៀនដោយយកចិត្តទុកដាក់ចំពោះសិស្ស**"។

គម្រោង CO-SAVED ត្រូវបានប្រតិបត្តិដោយអង្គការ ខេប ដោយសហការជាមួយអង្គការ AeA ក្រោមជំនួយហិរញ្ញប្បទានសហភាពអឺរ៉ុប។ គម្រោង CO-SAVED បានផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀន នាយកសាលា បណ្ណារក្ស ការប្រជុំឪពុកម្តាយ គណៈកម្មការគ្រប់គ្រងសាលារៀន ប្រព័ន្ធរំលឹកទុកជាមុន សម្ភារៈអាហារូបករណ៍ ជួសជុលបន្ទប់សិក្សា បណ្ណាល័យ ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ថវិកាអភិវឌ្ឍន៍សាលា បង្កើតសាលាមត្តេយ្យសហគមន៍ ជួសជុល និងកសាងបង្គន់អនាម័យ កន្លែងលាងដៃ ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់សិស្សជាកូនអ្នកនេសាទនៅក្នុងគម្រោង ដោយធ្វើសកម្មភាពសំខាន់ៗបង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងគុណភាពសិក្សារបស់កុមារថ្នាក់បឋមសិក្សានៅក្នុងតំបន់ និងបង្កើនការចុះឈ្មោះចូលរៀន ព្រមទាំងពង្រឹងគុណភាពសិក្សាសម្រាប់សិស្សអនុវិទ្យាល័យផងដែរ។ ថវិកាអភិវឌ្ឍន៍សាលាបានជួយសម្រួលបន្ទុកច្រើនដល់សាលាបឋមសិក្សា កោះគ្រឹស្នា ក្នុងការដឹកនាំ និងគ្រប់គ្រងការអប់រំកុមារ និងយុវជនឱ្យទទួលបានលទ្ធផលល្អប្រសើរជាលំដាប់៕

អនុវិស័យទី ៥

# កម្មវិធីអំណានថ្នាក់ដំបូង

"នៅពេលអ្នករៀនអាន អ្នកនឹងមានសេរីភាពរហូត"។

# Early Grade Reading

*Once you learn to read, you will be forever free.*



# សិស្សរៀនត្រួតថ្នាក់ ជាបញ្ហាចម្បងមួយក្នុងសាលារៀន



មិត្តជួយមិត្តនៅពេលចេញលេងជាសកម្មភាពមួយដើម្បីជួយឱ្យកុមារមានអារម្មណ៍ថារីករាយក្នុងការសិក្សាជាមួយកុមារដទៃ។

ការត្រួតថ្នាក់របស់សិស្សបឋមសិក្សានៅកម្ពុជា គឺជាបញ្ហាចម្បងដែលមាននៅក្នុងប្រព័ន្ធអប់រំកម្ពុជា ជាពិសេសនៅក្នុងថ្នាក់បឋមសិក្សាកម្រិតទាបៗ (ថ្នាក់ទី១ ដល់ទី៣)។ បច្ចុប្បន្ននេះ អង្គការ ខេប មានគម្រោងចំនួនប្រាំបីដែលធ្វើការលើកម្មវិធីអំណានថ្នាក់ដំបូងរួមមាន៖ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII), គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម(CO-SAVED) ,គម្រោងងាយស្រួលរៀន(E2Lក្រចេះ និងព្រៃវែង),គម្រោងកុមារកម្ពុជារីករាយ(HCC) កម្មវិធីសាលារៀនជំនាន់ថ្មីកម្រិតបឋមសិក្សា និងគម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH/BMZ) និងគម្រោងសហគមន៍នៃសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិចតំបន់១ (FOSTER) ជួយអន្តរាគមន៍ដល់សាលារៀនលើការសិក្សារបស់សិស្ស។

ដើម្បីចូលរួមកាត់បន្ថយសិស្សត្រួតថ្នាក់ និងលើកកម្ពស់ការសិក្សារបស់សិស្សរៀនយឺតឱ្យមានភាពល្អប្រសើរឡើង គម្រោងបានជួយគាំទ្រលើកម្មវិធីបំប៉នសិស្សរៀនយឺតដែលជាសកម្មភាពដ៏សំខាន់មួយ ដើម្បីជួយកែលម្អគុណភាពអប់រំ និងបង្កភាពងាយស្រួលចូលសាលារៀនដល់កុមារនៅតំបន់ដាច់ស្រយាលក្នុងការឆ្លើយតបទៅនឹងគោលដៅអប់រំសម្រាប់ទាំងអស់គ្នារបស់រាជរដ្ឋាភិបាលកម្ពុជា។

**សូមអានបន្តទំព័រ២៩...**



សិស្សរៀនយឺតត្រូវការការយកចិត្តទុកខ្លាំងពីលោកគ្រូអ្នកគ្រូ និងសហការជាមួយអាណាព្យាបាលដើម្បីធ្វើការសិក្សារបស់ពួកគេល្អប្រសើរឡើង។



សិស្សរៀនយឺត ជាសិស្សដែលធ្លាក់មធ្យមភាគក្នុងឆមាសទីមួយ ហើយពួកគេនឹងទទួលបានការបំប៉នបន្ថែម។

...តពីទំព័រ២៨ កម្មវិធីបំប៉នសិស្សរៀនយឺត គឺជាការបង្រៀនមេរៀនឡើងវិញនូវចំណុចណាដែលសិស្សមិនទាន់យល់ដើម្បីជាជំនួយ ជាពិសេសដល់សិស្សម្នាក់ៗទៅតាមតម្រូវការរបស់ពួកគេ ហើយសកម្មភាពនេះធ្វើឡើងនៅក្រៅម៉ោងសិក្សារៀងរាល់ថ្ងៃព្រហស្បតិ៍ នៅដើមឆមាសទី២ នៃឆ្នាំសិក្សា ដោយមានរយៈពេល ១៦សប្តាហ៍ ដោយដកទុកមួយសប្តាហ៍សម្រាប់ធ្វើការវាយតម្លៃ។ ការបំប៉នសិស្សរៀនយឺតដំណើរការបាន ត្រូវការជ្រើស រើសគ្រូ សិស្ស ទីកន្លែង និងការជួយផ្តល់បច្ចេកទេសដល់គ្រូ។ កម្មវិធីនេះមានគោលបំណងជួយដល់សិស្សរៀនខ្សោយ សិស្សពិការ សិស្សមកពីស្ថានភាពខ្វះខាត និងសិស្សអសមត្ថភាពក្នុងការសិក្សា ឱ្យរៀនជាប់មធ្យមភាគវិញនៅចុងឆ្នាំសិក្សា។ ដូច្នេះ លោកគ្រូអ្នកគ្រូត្រូវយកចិត្តទុកដាក់ដល់សិស្សដែលធ្លាក់មធ្យមភាគក្នុងឆមាសទី១ ធ្វើយ៉ាងណាជួយពួកគេរៀនជាប់មធ្យមភាគវិញនៅក្នុងឆមាសទី២។ លោកគ្រូអ្នកគ្រូដែលត្រូវបានជ្រើសរើសចូលក្នុងកម្មវិធីបំប៉នសិស្សរៀនយឺត គឺជាគ្រូដែលសកម្មក្នុងការងារបង្រៀនសិស្ស ហើយជាគ្រូដែលមានទំនោរលើការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល រឺការបង្រៀនតាមបែបសហការ។ មុននឹងចាប់ដំណើរការកម្មវិធីបំប៉នសិស្សរៀនយឺតនេះ កម្រងសាលារៀននីមួយៗត្រូវរៀបចំធ្វើបុរេតេស្ត ជាមុនសិនដើម្បីស្វែងរកចំនុចខ្សោយ និងចំណុចខ្លាំងរបស់សិស្ស។ បន្ទាប់មកនៅពាក់កណ្តាលកម្មវិធីបំប៉នត្រូវរៀបចំធ្វើតេស្តម្តងទៀត ដើម្បីវាស់ពីការរីកចម្រើនរបស់សិស្ស។ នៅដំណាក់កាលចុងក្រោយត្រូវរៀបចំធ្វើតេស្តសរុបមួយទៀត។ វិញ្ញាសារតេស្តនីមួយៗត្រូវរៀបចំដោយគណៈកម្មការបច្ចេកទេសប្រចាំកម្រង ហើយត្រូវរៀបចំកែដោយផ្លាស់ប្តូរគ្នា។ ការរៀបចំដំណើរការបំប៉ននេះ ត្រូវមានការចូលរួមសហការគ្នារវាង ការិយាល័យអប់រំស្រុក ប្រធានសមាជិកក្រុមចម្បង នាយកសាលានីមួយៗក្នុងកម្រង និងគ្រូបង្រៀនបំប៉នផ្ទាល់។ ចំពោះការចាត់ចែងថវិកា ត្រូវពិនិត្យទៅតាមថវិកាដែលបានកំណត់ក្នុងផែនការអភិវឌ្ឍកម្រងសាលារៀន។

ការបំប៉នសិស្សរៀនយឺត វាមានសារៈសំខាន់ណាស់ក្នុងការបង្រៀនមេរៀនឡើងវិញនូវចំណុចណាដែលសិស្សមិនទាន់យល់ និងអនុវត្តន៍លំហាត់ឱ្យបានច្រើនពីងាយស្រួលទៅស្មុគស្មាញគឺធ្វើយ៉ាងណាផ្តល់នូវតម្រូវការ ពិសេសដល់សិស្ស ដើម្បីឱ្យពួកគេមានលទ្ធភាពទទួលយកនូវចំណេះដឹងពេញលេញសម្រាប់ធ្វើការបន្តការសិក្សារបស់ខ្លួននៅឆ្នាំបន្ទាប់ ដូចនេះគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនត្រូវមានឆន្ទៈខ្ពស់ក្នុងការបំពេញកិច្ចការនេះឱ្យបានជោគជ័យនិងប្រកបដោយប្រសិទ្ធភាព៕(**ដកស្រង់ចេញពីសៀវភៅបំប៉នសិស្សរៀនយឺតរបស់អង្គការ ខេប**)



ការបំប៉នសិស្សរៀនយឺត ធ្វើឱ្យសិស្សានុសិស្សអនុវត្តលំហាត់ឱ្យបានច្រើនពីងាយស្រួលទៅស្មុគស្មាញហើយឆាប់ចាប់បានមេរៀនសំខាន់ៗ។

អនុវិស័យទី ៦

# កម្មវិធីមត្តេយ្យសិក្សា

“បង្កើនគំនិតមួយសម្រាប់កុមារមួយនាក់ក្នុងពេលតែមួយ”។

# Preschool Programming

*Enriching the mind one child at a time.*



# តើកុមារត្រូវការអាហារូបត្ថម្ភអ្វីខ្លះសម្រាប់ការលូតលាស់?



កុមារមានអាហារសម្រន់រាល់ព្រឹកនៅសាលាមត្តេយ្យសហគមន៍ក្នុងឃុំហាន់ជ័យ ដើម្បីទ្រទ្រង់រាងកាយ និងការលូតលាស់ដល់កុមារ។

ជាទូទៅសិស្សទទួលរងនូវបញ្ហាអាហារូបត្ថម្ភផ្សេងៗជាច្រើនដូចជា កង្វះមីក្រូសារជាតិកម្រិតខ្ពស់ អត្រាលើសទម្ងន់និងធាត់ជ្រុល និងកង្វះអាហារូបត្ថម្ភយូរអង្វែង។ ការកើនឡើងយ៉ាងឆាប់រហ័សនូវប្រជាប្រិយភាពរបស់អាហារកែច្នៃក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើគុណភាពរបបអាហារ។ ជាក់ស្តែង ការទទួលទានបាយ សាច់ និងត្រីមានបរិមាណខ្ពស់ ចំណែកការទទួលទានផ្លែឈើ បន្លែ និងប្រភេទប្រូតេអ៊ីនរួមមាន៖ ទឹកដោះគោ ស៊ុត និងគ្រាប់ធញ្ញជាតិ នៅមានកម្រិតទាបខ្លាំងជាងកម្រិតដែលបានណែនាំដោយគោលការណ៍អន្តរជាតិនៅឡើយ។ ទោះបីជាមានវឌ្ឍនភាពខ្លះៗក្នុងការកាត់បន្ថយអត្រានៃភាពស្គមស្គាំងក៏ដោយ កង្វះអាហារូបត្ថម្ភនៅតែជាបញ្ហាដែលបន្តកើតមាននៅក្នុងកម្រិតគ្រួសារ។ ហេតុដូចនេះ ខេបបានផ្តល់ស្បៀងអាហារដល់សិស្សមត្តេយ្យសិក្សា ដោយបានរួមចំណែកលើកកម្ពស់លទ្ធផលផ្នែកអាហារូបត្ថម្ភ ក៏ដូចជាវត្តមាន ការផ្តោតអារម្មណ៍ និងការរៀនសូត្ររបស់សិស្ស។ ការគាំទ្រសកម្មភាពសាលាមត្តេយ្យសហគមន៍ក្នុងឃុំហាន់ជ័យ គឺជាសកម្មភាពដ៏សំខាន់មួយរបស់គម្រោងកុមារកម្ពុជារីករាយ(HCC)។គម្រោងមិនត្រឹមតែជួយគាំទ្រដល់មត្តេយ្យសិក្សាឱ្យមានគុណភាពខ្ពស់នៅក្នុងសហគមន៍តែប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់ទាំងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់គ្រូបង្រៀន មានអាហារសម្រន់ដល់កុមារ និងមានយុទ្ធនាការសម្រាប់ជួយចុះឈ្មោះកុមារចូលរៀនថែមទៀតផង។

យ៉ាងណាក៏ដោយការផ្តល់ស្បៀងអាហារតាមសាលារៀននេះ គ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះនៃរបបអាហាររបស់កុមារ វាមិនអាចសំដៅដល់ការដោះស្រាយបញ្ហាទទួលទានអាហារនៅផ្ទះបានឡើយ។ ដូច្នេះ សាលារៀននៅតែជាវេទិកាមួយដែលផ្តល់លទ្ធភាព និងឱកាសក្នុងការលើកកម្ពស់របបអាហាររបស់កុមារ ឱ្យកាន់តែទូលំទូលាយ។ ការចូលរួមចំណែករបស់គម្រោងបានជួយឱ្យសាលារៀនគោលដៅអាចនឹងសម្រេចបានគោលនយោបាយជាតិស្តីពីសុខភាពសិក្សាឆ្នាំ ២០១៩ ផែនការសកម្មភាពជាតិស្តីពីសុខភាពក្នុងវ័យសិក្សា និងគោលការណ៍ណែនាំស្តីអំពីបទដ្ឋានលើកកម្ពស់សុខភាពសិក្សា ដែលទាំងអស់នេះមានរួមបញ្ចូលនូវអាទិភាពជាយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការកែលម្អឥរិយាបថទទួលទានអាហារ និងឥរិយាបថសុខភាពរបស់សិស្ស និងអាណាព្យាបាលសិស្ស។

នៅក្នុងឆ្នាំសិក្សាថ្មីនេះ យើងសង្កេតឃើញថាការលូតកំពស់ និងគីឡូរបស់សិស្សបានល្អប្រសើរ ពីព្រោះយើងបានតាមដានសិស្សជារៀងរាល់ខែ ដោយសិស្សម្នាក់ត្រូវថ្លឹងគីឡូ និងវាស់កម្ពស់ម្តងក្នុងមួយខែ។

គម្រោងកុមារកម្ពុជារីករាយ ប្រតិបត្តិដោយអង្គការ ខេប ទទួលហិរញ្ញប្បទានពីមូលនិធិគីនធាន ដើម្បីបង្កើនសេវាគុណភាពមត្តេយ្យនៅក្នុងឃុំហាន់ជ័យ៕



កុមារត្រូវធ្វើការថ្លឹងគីឡូ និងវាស់កម្ពស់រៀងរាល់មួយខែម្តងដើម្បីតាមដានការលូតលាស់របស់កុមារ។

អនុវិស័យទី ៧

# រចនាបថហេដ្ឋារចនាសម្ព័ន្ធ

"ធ្វើឱ្យទម្រង់ការអប់រំស្របតាមតម្រូវការ និងដើរតួនាទីថ្មីៗ"។

# Infrastructure Design

*Making educational forms that follow new needs and functions.*













# ហេតុអ្វីបានជាហេដ្ឋារចនាសម្ព័ន្ធសាលាគោលដៅអភិវឌ្ឍន៍លឿន ?


សាលារៀនមានបណ្ណាល័យស្អាត ទាក់ទាញសិស្សានុសិស្សចូលមកអានសៀវភៅ។

សាលារៀនមានសោភ័ណភាព ជាកត្តាមួយធ្វើឱ្យសិស្សានុសិស្សមករៀនយ៉ាងទៀងទាត់។ ដើម្បីក្លាយជាសាលារៀនពិតប្រាកដទាមទារឱ្យអ្នកដឹកនាំ គឺនាយកសាលា និងគណៈគ្រប់គ្រងសាលារៀន ចេះរៀបចំសាលារៀនឱ្យក្លាយជាបរិស្ថានអប់រំ ឬជាមជ្ឈមណ្ឌលដែលបណ្ដុះបណ្ដាលធនធានមនុស្សពេញលេញនោះ ពួកគាត់ត្រូវចេះស្វះស្វែងសហការជាមួយសហគមន៍ ជាពិសេសអង្គការដៃគូ។ ការចូលរួមគាំទ្រ និងអន្តរាគមន៍ពីគម្រោងកុមារកម្ពុជារីករាយ(HCC)ដល់សាលារៀនគោលដៅចំនួន៤០ បានផ្លាស់ប្ដូរសាលារៀនធម្មតាក្លាយទៅជាសាលារៀនគំរូនៅក្នុងសហគមន៍របស់ខ្លួន។ គម្រោងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញ និងលើកកម្ពស់គុណភាពអប់រំ ជាពិសេសតំបន់ដាច់ស្រយាល។ សកម្មភាពសំខាន់ៗដែលគម្រោងបានចូលរួមចំណែកសម្រាប់អភិវឌ្ឍន៍សាលារៀនរួមមាន៖ ១)ការបង្កើតបណ្ណាល័យទំនើបដែលទាក់ទាញសិស្សានុសិស្ស ពីព្រោះវាជាកន្លែងអានមួយដែលមានបរិស្ថានស្អាត និងសម្បូរសៀវភៅអានជាច្រើន។ ២)កសាងសមត្ថភាពគ្រូកិច្ចសន្យា៖ គម្រោងបានជួលគ្រូប្រឹក្សាគរុកោសល្យពេញម៉ោង ដើម្បីជួយពន្លឿនដល់ការគាំទ្រចំពោះគ្រូកិច្ចសន្យាសម្រាប់លើកកម្ពស់ការបង្រៀន និងរៀនរបស់ពួកគាត់។ ៣) ការតាមដានការប្រើប្រាស់ថវិកាអភិវឌ្ឍន៍សាលារៀន មានសាសារៀនចំនួន២០ប៉ុណ្ណោះ ដែលបានទទួលជំនួយថវិកាអភិវឌ្ឍសាលារៀនសម្រាប់ដំណើរការកម្មវិធីដោយខ្លួនឯងក្នុងចំណោមសាលារៀនគោលដៅទាំងអស់។ ៤)ការគ្រប់គ្រងការវាយតម្លៃអំណានថ្នាក់ដំបូង នៅដើមគ្រា និងពាក់កណ្ដាលគ្រា ដើម្បីតាមដានការសិក្សារបស់សិស្ស។ ៥)ការពង្រឹងថ្នាក់រៀន៖ គម្រោងបានផ្ដល់វគ្គបណ្ដុះបណ្ដាលជាច្រើន ដល់លោកគ្រូអ្នកគ្រូ ជាជំនួយក្នុងការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ ៦)ការគ្រប់គ្រងសាលារៀន និងការបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំ៖ នាយកសាលាទទួលបានការគាំទ្រជាបន្តបន្ទាប់ដើម្បីជួយពួកគាត់ក្នុងការដឹកនាំសាលារៀនឱ្យមានការរីកចម្រើន និងធ្វើការងារកាន់តែជិតស្និទ្ធជាមួយសហគមន៍។ ៧)ការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់៖ គម្រោងបានដាក់សាកល្បងនូវកម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក្នុងសាលារៀនចំនួន៥របស់ខ្លួន ដោយផ្អែកលើគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដោយផ្ដោតលើបណ្ណាល័យ និងកែលម្អសាលារៀនជុំទី១ឱ្យមានស្តង់ដាដូចគ្នាទៅនឹងសាលារៀនជុំបន្តបន្ទាប់ទៀត។

តាមសាលារៀនគោលដៅនីមួយៗ ទីធ្លាសាលារៀនមានសណ្ដាប់ធ្នាប់ ថ្នាក់រៀនមានការតុបតែងលម្អ លោកគ្រូអ្នកគ្រូមានការអភិវឌ្ឍសមត្ថភាពជាប្រចាំលើវិធីសាស្ត្របង្រៀន និងរៀន។ នាយក មន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុកបានសហការជាមួយគម្រោងបានយ៉ាងល្អ ចំណុចល្អទាំងនេះបានធ្វើឱ្យសាលារៀនមានភាពរីកចម្រើនហើយការផ្ដល់សេវាអប់រំដល់កុមារមានភាពល្អប្រសើរឡើង។

គម្រោងកុមារកម្ពុជារីករាយ ប្រតិបត្តិដោយអង្គការខេប ទទួលហិរញ្ញប្បទានពីមូលនិធិគីនឆាន ដើម្បីកែលម្អសមត្ថភាពគ្រប់គ្រងដៃគូនៅមូលដ្ឋាន ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ៕


បរិស្ថានក្រៅថ្នាក់រៀនមានទីធ្លាស្អាត មានសោភ័ណភាព ជាផ្នែកមួយជំរុញឱ្យសិស្សានុសិស្សមករៀនយ៉ាងទៀងទាត់។

អនុវិស័យទី

# ៨

# ការអភិវឌ្ឍបណ្ណាល័យ

“បណ្ណាល័យសាលារៀនៈ ជាសោរសម្រាប់អតីតកាល និងជាទ្វារសម្រាប់អនាគត”។

## Library Development

*The School Library Key to the Past and Gateway to the Future.*



# បណ្ណាល័យនៅតែដើរតួនាទីសំខាន់សម្រាប់សិស្សនាពេលបច្ចុប្បន្ន



សកម្មភាពសិស្សចូលក្នុងបណ្ណាល័យអានសៀវភៅរឿងនិទាន និងលេងល្បែងសិក្សា អំឡុងពេលទំនេរ និងពេលចេញលេងពីការសិក្សា។

ភាពរីកចម្រើននៃបច្ចេកវិទ្យាធ្វើឱ្យសិស្សានុសិស្សនាពេលបច្ចុប្បន្ននេះ អាចស្វ័យសិក្សានៅតាមផ្ទះ និងអានឯកសារតាមរយៈប្រព័ន្ធអេឡិចត្រូនិចបានគ្រប់ពេល និងគ្រប់ទីកន្លែង។ យ៉ាងណាក៏ដោយនៅតែមានសិស្សភាគច្រើនបន្តជ្រើសរើសទៅសិក្សាស្រាវជ្រាវ និងអានសៀវភៅនៅទីតាំងបណ្ណាល័យផ្ទាល់ ដោយសារតែមានមិត្តភាពចូលរួមអានបន្ទប់មានផាសុកភាពនិងងាយផ្តោតអារម្មណ៍លើការអាន។

គម្រោងនៅក្នុងអង្គការខេប បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងវិស័យអប់រំនៅកម្ពុជាឱ្យមានលក្ខណៈល្អប្រសើរឡើង។ នៅក្នុងសាលារៀន បណ្ណាល័យជាផ្នែកមួយជួយអភិវឌ្ឍធនធានចំណេះដឹងដល់សិស្សានុសិស្សហើយការជួយរៀបចំបណ្ណាល័យធម្មតាឱ្យក្លាយជាបណ្ណាល័យសតវត្សរ៍ទី២១ គឺជាសកម្មភាពដ៏សំខាន់របស់គម្រោងនៅក្នុងសាលារៀនគោលដៅ។បច្ចុប្បន្ន មានគម្រោងដែលបន្តជួយអភិវឌ្ឍបណ្ណាល័យទំនើបដល់សាលារៀនគោលដៅរួមមាន៖ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII), គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED), គម្រោងងាយស្រួលរៀន (E2L), កម្មវិធីសាលារៀនជំនាន់ថ្មី (NGS) និងគម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (BMZ/REACH IV)។

ដើម្បីចូលរួមចំណែកអភិវឌ្ឍបណ្ណាល័យទំនើបនៅក្នុងសាលារៀនគោល គម្រោងបានសហការយ៉ាងជិតស្និទ្ធជាមួយនាយកគណៈគ្រប់គ្រងសាលារៀន មន្ទីរ-ការិយាល័យអប់រំយុវជន និងកីឡា បានធ្វើការគៀរគរថវិកាពីសហគមន៍ និងសប្បុរសជនក្នុងការដំណើរការអភិវឌ្ឍសាលារៀនរួមមាន៖ ការជួសជុលបន្ទប់ថ្នាក់រៀនចាស់ទៅជាបណ្ណាល័យទំនើបបំពាក់គ្រឿងសង្ហារិម តុ ទូ កង្ហារ សៀវភៅឱ្យក្លាយទៅជាកន្លែងទាក់ទាញសម្រាប់សិស្សានុសិស្សក្នុងការអាន។ តួយ៉ាងដូចជាបណ្ណាល័យនៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី មានទាំងថេបប្លែត និងកុំព្យូទ័រ ជាពិសេសមានភ្ជាប់អ៊ីនធើណិតដើម្បីជួយសម្រួលក្នុងការសិក្សារៀនសូត្រ និងការរុករកស្រាវជ្រាវឱ្យកាន់តែទូលំទូលាយ។

អ្នកគ្រូ ជា ដានី ជាបណ្ណារក្សនៅសាលាបឋមសិក្សាជៀសបានមានប្រសាសន៍ថា “**គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII) បានជួយឱ្យបណ្ណាល័យដំណើរការ និងក្លាយទៅជាទីពេញចិត្តរបស់កុមារ និងសហគមន៍ ហើយធ្វើឱ្យសាលាអាចឈានដល់សាលារៀនជំនាន់ថ្មី។ តាំងតែពីមានបណ្ណាល័យស្អាតមក សិស្សានុសិស្សចូលបណ្ណាល័យអាន និងខ្ចីសៀវភៅច្រើនជាងមុន។ អ្នកគ្រូបានបន្ថែមទៀតថា មានសិស្សខ្លះរៀនវេនព្រឹកទេ តែដល់ពេលថ្ងៃពួកគាត់ចូលមកលេងក្នុងបណ្ណាល័យអានសៀវភៅ លេងថេបប្លែត។ នេះ ជាការប្រែប្រួលមួយ គួរឱ្យកត់សម្គាល់នៅក្នុងសាលារៀន**”។

ទោះបីជាមានបណ្ណាល័យនៅលើប្រព័ន្ធអនឡាញសម្រាប់សិស្សានុសិស្ស និងសាធារណជនអាចសិក្សាបានក៏ពិតមែន តែការមកបណ្ណាល័យផ្ទាល់នៅតែជាកន្លែងពេញនិយមសម្រាប់សិស្សក្នុងការសិក្សាស្រាវជ្រាវ និងអាចផ្តោតអារម្មណ៍លើការអាន។

បណ្ណាល័យនៅតែជាកន្លែងស្ងប់ស្ងាត់ និងដើរតួនាទីយ៉ាងសំខាន់ក្នុងសម័យឌីជីថលសម្រាប់សហគមន៍៕

អនុវិស័យទី ៥

# កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

“បំណិនជីវិតទទួលបានអត្ថប្រយោជន៍ពីការអប់រំសកម្មភាពគ្រូបង្រៀន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកម្មវិធីសិក្សាឌីណាមិក”។

## Life Skills Education & Career Counseling

*Life Skills benefit from proactive education, Qualified Instructors, Dynamic Curriculum.*













# ប្រជុំផ្ទុះបញ្ចាំងពីការអនុវត្តកម្មវិធីបំណិនជីវិតតាមសាលាគោលដៅ



បំណិនជីវិត ជាផ្នែកមួយធ្វើឱ្យសិស្សានុសិស្សបានសិក្សាស្វែងយល់បន្ថែមពីសកម្មភាពរស់នៅប្រចាំថ្ងៃ។

គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) បានរៀបចំវគ្គសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលកម្មវិធីសិក្សាបំណិនជីវិត Gap Inc. P.A.C.E. ត្រូវបានធ្វើឡើងនៅទីតាំង៣ផ្សេងគ្នាក្នុងខេត្តចំនួន ៣ ដូចជា ខេត្តសៀមរាប ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ កាលពីថ្ងៃទី១៧,១៩ និងទី២៣ ខែមករា ឆ្នាំ ២០២៣។ សិក្ខាសាលានេះ រៀបចំឡើងក្រោមការសហការសម្របសម្រួលដោយក្រុមការងារគម្រោង(PWGs) មកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងបុគ្គលិកគម្រោងដែលត្រូវធ្វើការបណ្តុះបណ្តាលដល់គ្រូក្នុងសាលារៀនគោលដៅសរុបចំនួន៣៨ ដែលក្នុងនោះមានសាលាថ្មីចំនួន ២៤ និងសាលាគោលដៅចាស់ចំនួន៩ (សម្រាប់គ្រូដែលបានអវត្តមានក្នុងការចូលរួមសិក្ខាសាលារំលឹកឡើងវិញ) និងសាលារៀនចំនួន៥ដែលបានជ្រើសរើសជំនួសសាលារៀនគោលដៅចាស់ដែលមិនអាចដំណើរការបង្រៀនកម្មវិធីបំណិនជីវិតក្នុងឆ្នាំសិក្សាថ្មីនេះ។ សិក្ខាសាលានេះមានសមាសភាពចូលរួមសរុបចំនួន ១៤៤នាក់ (ស្រី ៦១នាក់) រួមមាន៖ ក្រុមការងារគម្រោងមកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយក/នាយិកាសាលាគោលដៅ និងលោកគ្រូ-អ្នកគ្រូបង្រៀនកម្មវិធីបំណិនជីវិត។

សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណង ឱ្យសិក្ខាកាម៖១-ស្គាល់អំពីគម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG)។ ២-យល់ដឹងពីការប្រើប្រាស់សៀវភៅបំណិនជីវិត Gap Inc. P.A.C.E.។ ៣-អនុវត្តបង្រៀនសាកល្បងដែលឆ្លុះបញ្ចាំងពីការសិក្សាបែបចូលរួមក្នុងសៀវភៅបំណិនជីវិត Gap Inc. P.A.C.E.។

អំឡុងវគ្គសិក្ខាសាលា សិក្ខាកាមបានបង្រៀនសាកល្បងនូវមេរៀនមួយចំនួនដែលមាននៅក្នុងសៀវភៅបំណិនជីវិតសម្រាប់ក្រុមសិស្សវ័យជំទង់ និង ពេញវ័យដែលមានខ្លឹមសារដូចខាងក្រោម៖ ខ្ញុំ និងអ្នកដទៃ, ការចរចាពីតួនាទីយេនឌ័រ, ការប្រាស្រ័យទាក់ទងដោយកាយវិការ, តើការងារបង្កើតឱ្យមានតួនាទីយេនឌ័រដូចម្តេច, ភាពជាក្មេងស្រី, រាងកាយរបស់ខ្ញុំ!ការគោរពរបស់ខ្ញុំ!, ស្ត្រី និងការងារ, អំណាចដើរ, ការយល់ដឹងអំពីយេនឌ័រ, តើខ្ញុំជានរណា? និង ការកសាងការឱ្យតម្លៃលើខ្លួនឯង៖ ការលើកទឹកចិត្ត។

ក្រោយបញ្ចប់វគ្គសិក្ខាសាលា សិក្ខាកាមបានធ្វើតេស្តវាយតម្លៃក្រោយវគ្គ ដែលមានសិក្ខាកាមចូលរួមវាយតម្លៃសរុបចំនួន១៣៧ នាក់ (គ្រូបង្រៀន និងនាយក/នាយិកា) ហើយ៨៤% នៃសិក្ខាកាមទាំងអស់បានយល់ដឹងច្បាស់ពីការប្រើប្រាស់សៀវភៅបំណិនជីវិត Gap Inc. P.A.C.E. ក្នុងការបង្រៀន និងរៀនដើម្បីកសាងបំណិន និងប្រសិទ្ធភាពដល់កុមារីឱ្យមានទំនុកចិត្ត សមត្ថភាពធ្វើការសម្រេចចិត្ត និងចេះធ្វើផែនការសម្រាប់អនាគតរបស់ខ្លួន។

គួររម្លឹកថា គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) ទទួលបានហិរញ្ញប្បទានពីក្រុមហ៊ុន Gap Inc ដែលមានគោលបំណងធ្វើឱ្យមានការផ្លាស់ប្តូរប្រែកបដោយសុខភាពល្អ និងវិជ្ជមានទៅជាមនុស្សពេញវ័យខណៈពេលដែលការទទួលស្គាល់ និងដោះស្រាយភាពងាយរងគ្រោះ និងវិសមភាពយេនឌ័រ៕



លោកគ្រូអ្នកគ្រូដែលជាក្រុមការងារគម្រោងបានចូលរួមយ៉ាងសកម្មដើម្បីផ្សព្វផ្សាយកម្មវិធីបំណិនជីវិត។

អនុវិស័យទី ១០

# កម្មវិធីឆ្លើយតបនឹងវិស័យអប់រំ ក្នុងបរិបទជំងឺកូវីដ-១៩

## Covid19 Response & Recovery Programming



# ការប្រើប្រាស់កញ្ចប់សិក្សាបំប៉នបន្ថែមដល់សិស្សដែលរៀនយឺត




ការបង្កើតកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី២ ដល់ទី៦ ក្នុងគោលបំណងផ្តល់ឱកាសជួយជំរុញ និងលើកទឹកចិត្តសិស្សបានសិក្សារៀនសូត្រផ្សារភ្ជាប់ជាមួយសកម្មភាពល្បែងសិក្សាព្រមទាំងសកម្មភាពដទៃទៀតពីកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមភាសាខ្មែរ និងគណិតវិទ្យាដោយបង្កើតឡើងនូវបរិយាកាសសប្បាយរីករាយដល់កុមារបានចូលរួមយ៉ាងសកម្មក្នុងថ្នាក់រៀន និងទទួលបានលទ្ធផលល្អប្រសើរទៅថ្ងៃមុខ។

កញ្ចប់ការសិក្សាបំប៉នបន្ថែម គឺជាឯកសារមួយចប់ដែលបានរៀបចំឡើងដើម្បីជួយសិស្សឱ្យឆាប់ចាប់បានមេរៀនដែលពួកគេបានបាត់បង់ ក្នុងអំឡុងពេលសាលារៀនបិទទ្វារ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយការប្រើប្រាស់កញ្ចប់ឯកសារនេះធ្វើសម្រាប់បង្រៀនបំប៉ននៅថ្ងៃព្រហស្បតិ៍ នៅពេលដែលលោកគ្រូអ្នកគ្រូផ្តល់វគ្គបំប៉នបន្ថែមដល់សិស្សដែលរៀនយឺត។

កញ្ចប់ឯកសារនេះត្រូវបានរៀបចំឡើងចំនួន៤ សំខាន់ៗ ដូចជា (១) កម្មវិធីសិក្សា គឺជួយសាលារៀនឱ្យរៀបចំធនធានបន្ថែមសម្រាប់ថ្នាក់បំប៉នបន្ថែមដើម្បីប្រើប្រាស់នៅសាលារៀន និងនៅផ្ទះសម្រាប់ធ្វើការស្វ័យសិក្សា។ (២) ការបង្រៀន គឺរៀបចំធនធានសិក្សាដើម្បីគាំទ្រគ្រូក្នុងការធ្វើការបង្រៀនបំប៉នបន្ថែម។ (៣)រចនាសម្ព័ន្ធឯកសារ មានន័យថាផ្តល់សេចក្តីណែនាំសម្រាប់ការប្រតិបត្តិថ្នាក់បំប៉នបន្ថែមនៅកម្រិតសាលារៀនសម្រាប់ថ្នាក់ទី២ ដល់ថ្នាក់ទី៦។ (៤) ការវាយតម្លៃ សំដៅលើការផ្តល់ឱ្យគ្រូនូវឧបករណ៍ធ្វើតេស្តវិភាគបញ្ហាការលំបាកនៃការសិក្សារបស់សិស្ស។ កម្មវិធីសិក្សារបស់កញ្ចប់ឯកសារនេះ គឺផ្តោតសំខាន់លើការរៀបចំខ្លឹមសារនៃសៀវភៅសិក្សាគោលឱ្យទៅជាសមត្ថភាពគោលដែលសង្ខេបខ្លីហើយច្បាស់ និងជួយគ្រូឆាប់យល់ដឹងកាន់តែប្រសើរពីរបៀបជួយសិស្សឱ្យទទួលបានចំណេះដឹងនៅក្នុងសមត្ថភាពគោលដែលពួកគេមិនទាន់បានរៀន។

គម្រោងរបស់អង្គការខេបចំនួនប្រាំបួនរួមមាន៖ គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌(CO-SAVED), គម្រោងងាយស្រួលរៀន(E2L)ខេត្តព្រៃវែង និងខេត្តក្រចេះ, គម្រោងកុមារកម្ពុជារីករាយ (HCC), មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី(NGPRC) កម្មវិធីសាលារៀនជំនាន់ថ្មី(NGS) បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍(REACH IV) ដែលបន្តជំរុញការប្រើប្រាស់កញ្ចប់ឯកសារនេះដល់លោកគ្រូអ្នកគ្រូតាមសាលារៀនគោលដៅ និងអ្នកពាក់ព័ន្ធរបស់គម្រោង ធ្វើយ៉ាងណាជួយឱ្យសិស្សរៀនយឺត ឱ្យជាប់មធ្យមភាគនៅឆមាសទី២ ក៏ដូចជាចូលរួមចំណែកកាត់បន្ថយអត្រាត្រួតថ្នាក់តាមសាលារៀនគោលដៅ។

កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមទាំងភាសាខ្មែរ និងគណិតវិទ្យាចាប់ពីថ្នាក់ទី២ដល់ទី៦ អាចស្វែងរកបាននៅលើគេហទំព័រផ្លូវការរបស់ក្រសួងអប់រំយុវជន និងកីឡា ជាពិសេសមានវីដេអូសម្រាប់បង្ហាញពីការប្រើប្រាស់ ក្នុងករណីលោកគ្រូអ្នកគ្រូមិនទាន់យល់ពីការប្រើប្រាស់កញ្ចប់ឯកសារនេះ។

# ព្រឹត្តិការណ៍ ចំណេះដឹង កំណាព្យ និងការសិក្សាស្រាវជ្រាវផ្សេងៗ

*“ការអភិវឌ្ឍតាមរយៈបណ្ដាញ និងនៅថ្នាក់មូលដ្ឋាន”។*

# Events, Knowledge, Poems, and Other Researches

*Development through Networking and Outreach.*











# អង្គការ ខេប បានចុះកិច្ចសន្យាជាមួយលោក ដែន ឌល់ណាសិន



កម្មវិធីសាលារៀនជំនាន់ថ្មីនឹងសាកល្បងអនុវត្តលើបច្ចេកវិទ្យាហ្គេមដើម្បីផ្តល់ឱ្យឱកាសបានសិក្សារៀនសូត្រនូវអ្វីដែលថ្មី។

នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) បានរៀបចំកិច្ចសន្យាទីប្រឹក្សាស្តង់ដារបស់ខ្លួនជាមួយលោក ដែន ឌល់ណាសិន (Dan Donaldson) ក្នុងគោលបំណងផ្តល់សេវាកម្ម និងការគាំទ្រសម្រាប់ការប្រឹក្សា ដែលនឹងនាំទៅដល់ក្របខ័ណ្ឌកម្មវិធីសិក្សាតាមបរិបទ ដើម្បីលើកកម្ពស់បច្ចេកវិទ្យាហ្គេមនៅកម្ពុជា។ កិច្ចសន្យានេះពិតជាជំនួយបច្ចេកទេសយ៉ាងសំខាន់ក្នុងការកែលម្អបច្ចេកវិទ្យាអប់រំទូទាំងប្រទេស ជាពិសេស គឺការដឹកនាំ KAPE និង TTOឱ្យក្លាយជាដៃគូអភិវឌ្ឍន៍វិស័យអប់រំយ៉ាងសកម្មរបស់ក្រសួងអប់រំយុវជននិងកីឡា ក្នុងការចូលរួមចំណែកកំណែទម្រង់អប់រំ៕

# បិទបញ្ចប់គម្រោង និងពិភាក្សាអំពីផែនការនិរន្តរភាព

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII) បានរៀបចំកម្មវិធីសិក្ខាសាលាបិទបញ្ចប់គម្រោង និងពិភាក្សាអំពីផែនការនិរន្តរភាព ដែលរៀបចំឡើងនៅសណ្ឋាគារ ភ្នំប្រុស ក្រុងកំពង់ចាម ដោយមានអ្នកចូលរួមសរុបចំនួន៧៣នាក់ រួមមាន៖ ប្រធាន-អនុប្រធានមន្ទីរ និងការិយាអប់រំយុវជន និងកីឡាខេត្ត-ស្រុក នាយក នាយិកា គ្រូបង្វឹកអំណាន គណៈគ្រប់គ្រងសាលារៀន លេខា និងបណ្ណារក្សដែលមកពីសាលារៀនគោលដៅទាំងអស់ចំនួន១៨ ស្ថិតក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សិក្ខាសាលានេះបានបង្ហាញនូវសមិទ្ធិផលនានារបស់គម្រោង និងបញ្ហាប្រឈមក្នុងការប្រតិបត្តិគម្រោង ព្រមទាំងសាផែនការសកម្មភាពនិរន្តរភាពនានាបន្ទាប់ពីគម្រោងបិទបញ្ចប់។


លោកគ្រូអ្នកគ្រូចំនួន៧៣នាក់ដែលមកពីសាលារៀនគោលដៅចំនួន១៧ និងមន្ទីរអប់យុវជ និងកីឡា។

លោក **ហ៊ិន ស៊ីមហួន** អនុប្រធានអង្គការ ខេប បានមានប្រសាសន៍ថា "គម្រោងត្រាក់៣/TRAC III បានលើកកម្ពស់បំណិនអានរបស់កុមារថ្នាក់ដំបូង តាមរយៈវិធីសាស្ត្រសរុបមួយ ដែលផ្តោតលើបរិស្ថានរៀនសូត្ររបស់កុមារ ដូចជា ការរៀនក្នុងថ្នាក់ រៀនក្រៅថ្នាក់ ការធ្វើតេស្ត និងកៀរគរអាណាព្យាបាល មាតាបិតាឱ្យចូលរួមជួយបង្រៀនកូននៅផ្ទះ និងមានសកម្មភាពផ្សេងៗជាច្រើន ដើម្បីធ្វើយ៉ាងណាឱ្យកុមារបង្កើនការសរសេរ និងអានដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការសិក្សាទៅថ្នាក់បន្ទាប់"។ **សូមអានបន្តទំព័រ៤១...**



លោក ហ៊ិន ស៊ីមហួន អនុប្រធានអង្គការ ខេប អញ្ជើញចូលរួមសិក្ខាសាលាបញ្ចប់គម្រោងរបស់គម្រោង TRACIII។

...តពីទំព័រ៤០ លោក **ស្លេះ តហៀត** ប្រធានគម្រោងត្រាក់៣(TRACIII)បានមានប្រសាសន៍ថា **"រយៈពេល ៥ឆ្នាំមកនេះ គម្រោងមានអ្នកទទួលផលសរុបមានចំនួន ៧ ៨០២ នាក់។ សមិទ្ធិផលសំខាន់ៗ របស់គម្រោង រួមមាន៖ ពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូលើវិធីសាស្ត្របង្រៀន និងរៀន កសាងបានបណ្ណាល័យសតវត្សរ៍ទី២១ដោយមានការចូលរួមបដិភាគពីសហគមន៍ជាមួយគម្រោង រៀបចំដំណើរការឱ្យមានកម្មវិធីជួយសិស្ស**មានតម្រូវការជាប្រព័ន្ធ(ឬហៅថាប្រព័ន្ធឆ្លើយតបរហ័ស)ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការ**បង្រៀន និងរៀន ព្រមទាំងមានការធ្វើតេស្តតាមប្រព័ន្ធអេឡិចត្រូនិកដើម្បីវាស់ស្ទង់បំណិនអំណានរបស់សិស្ស"**។

លោកស្រី **សុក គីមហ៊ាង** អ្នកសម្របសម្រួលមត្តេយ្យសិក្សាបានមានប្រសាសន៍ថា **"គម្រោងត្រាក់៣បានបង្កើតគម្រូមត្តេយ្យសិក្សាជំនាន់ថ្មីបានចំនួន៦ ដើម្បីផ្តល់វិធីសាស្ត្រថ្មីៗដល់កុមារតូចប្រកបដោយគុណភាព និងវិជ្ជាជីវៈគ្រប់ជ្រុងជ្រោយ រួមបញ្ចូលការចូលរួមរបស់សហគមន៍ក្រោមការពង្រឹងភាពជាដៃគូលើរចនាសម្ព័ន្ធដែលមានស្រាប់ ដោយបន្ថែមការគាំទ្របច្ចេកទេស ធនធានសម្ភារៈ និងហិរញ្ញវត្ថុពីគ្រប់អ្នកពាក់ព័ន្ធ"**។ លោកស្រីបានបន្តទៀតថាលទ្ធផលសម្រេចបានរបស់គម្រោងរយៈ៣ពេលឆ្នាំក្នុងការដំណើរការមត្តេយ្យជំនាន់ថ្មីមានបំពាក់គ្រឿងសង្ហារឹម ការតុបតែងថ្នាក់ និងរៀបកៀនមុខវិជ្ជា ការសាងសង់បង្គន់ ការរៀបចំសួរកុមារ បំពាក់ទូរទស្សន៍ និង ថេបប្លេតក្នុងកាបង្រៀន មានសម្ភារ និងល្បែងសិក្សាសំបូរបែបនៅក្នុងថ្នាក់ ការងារគម្រោង និងប្រជុំមាតាបិតាព្រមទាំងធ្វើតេស្ត ៥ឆ្នាំ និងតេស្តជំនាញទន់។

សិក្ខាកាមបានពិភាក្សា និងធ្វើការឆ្លុះបញ្ចាំងអំពីសកម្មភាពគម្រោងដែលបានអនុវត្តន៍កន្លងមក ដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀន កសាងសមត្ថភាពលោកគ្រូអ្នកគ្រូលើវិធីសាស្ត្របង្រៀន និងរៀន ជាពិសេសពង្រឹងជំនាញទន់ទាក់ទងនឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង ដល់នាយក នាយិកា ដើម្បីដឹកនាំសាលារៀនឱ្យក្លាយជាសាលារៀនកុមារមេត្រី។ ទន្ទឹមនឹងនោះ គម្រោងក៏បានផ្តល់ជូននូវប័ណ្ណសរសើរដល់លោកគ្រូអ្នកគ្រូឆ្នើមដែលបានខិតខំប្រឹងប្រែងជួយបំប៉នសិស្សរៀនយឺត ដើម្បីធានាបានថាការសិក្សារបស់ពួកមានលក្ខណៈល្អប្រសើរឡើង។

គម្រោងក៏បានសំណូមពរដល់សាលារៀនគោលដៅទាំងអស់បន្តសកម្មភាពដែលសាលារៀនបានសហការអនុវត្តកន្លងមកឱ្យអស់ពីលទ្ធភាពដើម្បីជាប្រយោជន៍រួមដល់កុមារក្នុងការពង្រឹងសមត្ថភាពអានរបស់ពួកគេ។សូមបញ្ជាក់ថា គម្រោងត្រាក់ទទួលបានហិរញ្ញប្បទានពីមូលនិធិ Phoenix ដែលផ្តោតលើការជួយកុមារពីអំណានថ្នាក់ដំបូង៕




លោក ឃឺត ប្រាឱនបើក ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ខេប បានប្រគល់ប័ណ្ណសរសើរជូនដល់នាយកសាលារៀនឆ្នើមដែលបានខិតខំអនុវត្តសកម្មភាពជាមួយគម្រោងកន្លងមក។

# ការទទួលប្រាក់សំណងពីក្រុមហ៊ុនរ៉ាប់រងអាយុជីវិត ហ្វតតេ



ការផ្ដល់ប្រាក់សំណងដល់ប្រពន្ធរបស់លោក ថន គីមធិន ដែលជាអតីតបុគ្គលិកខេបដែលបានទទួលមរណៈភាព។

លោក ថន គីមធិន ដែលជាអតីតប្រធានគម្រោងរបស់អង្គការ ខេប បានទទួលមរណៈភាពកាលពីឆ្នាំ២០២២ និងត្រូវជាស្វាមីរបស់អ្នកស្រី ភា សុភ័ស្ដ។ អ្នកស្រី ភា សុភ័ស្ដ បានអញ្ជើញមកទទួលប្រាក់សំណងផ្នែកធានារ៉ាប់រងអាយុជីវិតពីអង្គការ ខេប ដែលអង្គការបានបង់ជូនប្រចាំខែនៅក្រុមហ៊ុន ហ្វតតេ។

លោកស្រីបានមានប្រសាសន៍ក្នុងទឹកមុខរលីងរលោងថា "នាងខ្ញុំនឹងយកលុយសំណងនេះទៅធ្វើបុណ្យ១០០ថ្ងៃជូនស្វាមីរបស់ខ្ញុំ និងយកទៅពង្រីកមុខរបរបន្ថែម ព្រោះសព្វថ្ងៃនេះ ខ្ញុំប្រកបមុខរបរតិចតួច និងបន្ទាប់ទៀត នាងខ្ញុំនឹងយកលុយដែលសល់ពីនេះទៅដាក់ក្នុងកុងធនាគារសម្រាប់ឱ្យកូនបានបន្តការសិក្សា រៀនសូត្រចេះដឹង។ កាលពីមុន ខ្ញុំធ្លាប់មានស្វាមីជួយគិតគូរឱ្យ។ សំណងផ្នែកធានារ៉ាប់រងអាយុជីវិតនេះគឺពិតជួយដោះបន្ទុកគ្រួសារ ក្រោយពីស្វាមីរបស់នាងខ្ញុំបានទទួលមរណៈភាព"។

# លោក ឯម កុសល បានផ្ដល់អង្ករ និងអាវយឺតដល់សិស្សងាយរងគ្រោះ

គម្រោងកុមារកម្ពុជារីករាយ(HCC) សូមថ្លែងអរគុណដល់លោក ឯម កុសល ជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន ដោយបានជួយឧបត្ថម្ភអង្ករចំនួន ៤ បេ និងអាវយឺតចំនួន១៥០ តាមរយៈលោក អ៊ឹង ប៊ុន អធិការក្រុងកំពង់ចាម ដើម្បីចែកជូនសិស្សានុសិស្សក្រីក្រដល់សាលារៀនក្នុងតំបន់ដាច់ស្រយាលនៅក្នុងខេត្តរតនគិរី។

សូមជូនពរដល់លោក ឯម កុសល ព្រមទាំងក្រុមគ្រួសារទទួលបាននូវ ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕





លោក ឯម កុសល ជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន បានជួយឧបត្ថម្ភអង្ករ និងអាវជូនដល់សិស្សក្រីក្រក្នុងគម្រោង។

# ពិនិត្យ និងកែសម្រួលគោលនយោបាយ GEDSI របស់អង្គការខេប



កម្រងរូបភាពថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ប្រធានគម្រោង និងមន្ត្រីគម្រោងរបស់អង្គការខេបបានពិនិត្យ និងកែសម្រួលគោលនយោបាយ GEDSI។

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប/KAPE) បានរៀបចំវគ្គសិក្ខាសាលាស្តីពី គោលនយោបាយ GEDSI ដែលប្រព្រឹត្តិទៅក្រោមអធិបតីភាព លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការខេប លោក ហ៊ិន ស៊ីមហួន នាយករងប្រតិបត្តិអង្គការខេប និងលោកបណ្ឌិត អៀង សុធារ៉ា ប្រធានសមាគមពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-ជប៉ុន និងមានសិក្ខាកាមចូលរួមសរុបចំនួន ២៦នាក់ (ស្រី១១ នាក់) រួមមាន៖ ថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ប្រធានគម្រោង និងមន្ត្រីគម្រោងរបស់អង្គការខេប ព្រមទាំងប្រធានមណ្ឌលនៃអង្គការម៉ារីណុលកម្មអភិវឌ្ឍនមនុស្សថ្លង់ នៅភោជនីយដ្ឋាន សុខារ៉ាវី ខេត្តព្រៃវែង។

សិក្ខាសាលានេះ ធ្វើឡើងនៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ក្នុងគោលបំណង៖ ១-ស្វែងយល់ពីគោលការណ៍សំខាន់ៗដែលបានដាក់បញ្ចូលក្នុងគោលនយោបាយ GEDSI ២-ពិនិត្យ និងកែសម្រួលលើគោលនយោបាយ GEDSI និងបញ្ជ្រាបគោលនយោបាយនេះទៅកាន់ថ្នាក់ដឹក ប្រធានគម្រោង អំពីសមភាពយេនឌ័រ ជនមានពិការភាព និងបរិយាបន្នសង្គមដោយគ្មាននរណាម្នាក់ត្រូវបានទុកចោល។

សិក្ខាកាមចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាទៅលើគោលការណ៍មួយចំនួនដែលបានដាក់បញ្ចូលក្នុងគោលនយោបាយ GEDSI ដោយកែសម្រួលលើទស្សនវិស័យ និង ចំណុចសំខាន់ៗដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅក្នុងស្ថាប័នខេប។ ជាចុងក្រោយ គោលនយោបាយនេះនឹងត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល និង ថ្នាក់ដឹកនាំជាន់ខ្ពស់កែសម្រួលជាភាសាខ្មែរ៕

# ដំណើរទស្សនកិច្ចសិក្សាម្ចាស់ជំនួយនៅតាមសាលារៀនគោលដៅ

គម្រោងកុមារកម្ពុជារីករាយ (HCC) ប្រតិបត្តិដោយអង្គការ ខេប បានរៀបចំទទួលដំណើរទស្សនកិច្ចសិក្សាម្ចាស់ជំនួយរបស់ខ្លួនពីមូលនិធិគីនធាន ដោយមានលោកតា ហាតមុត ដឺស៊ីកេ ជាប្រធានដឹកនាំប្រតិភូ និងមានការអមដំណើរដោយលោកទិត្យ សីលា ជាប្រធានប្រចាំប្រទេសរបស់អង្គការកុមារកម្ពុជារីករាយ និងថ្នាក់ដឹកនាំសំខាន់ៗរបស់អង្គការខេប និងអង្គការដៃគូជាច្រើន ទៅកាន់សាលាបឋមសិក្សាហ៊ុនសែន ទឹកជ្រៅ ក្នុងខេត្តត្បូងឃ្មុំ ដើម្បីចុះត្រួតពិនិត្យ និងស្វែងយល់អំពីការអភិវឌ្ឍសាលារៀន គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ សិស្ស និងអ្នកពាក់ព័ន្ធដទៃៗទៀត ដើម្បីធ្វើការផ្ទះបញ្ជាំងអំពីសកម្មភាពក្នុងការអនុវត្តគម្រោងនៅតាមសាលារៀនគោលដៅនីមួយៗ។

លោក **តា ហាតមុត** បានជួបសំណេះសំណាលជាមួយនាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូយ៉ាងសប្បាយរីករាយ និងការទទួលស្វាគមន៍យ៉ាងកក់ក្តៅ។

ដំណើរទស្សនកិច្ចសិក្សានេះ បានពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនទាំងបរិវេណក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន និងបានជួបពិភាក្សាជាមួយប្រធានមន្ទីរ អប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ដើម្បីធ្វើយ៉ាងណាផ្តល់សេវាអប់រំមានគុណភាពដល់កុមារគ្រប់គ្នា ជាពិសេសកុមារនៅតំបន់ដាច់ស្រយាល៕


*ដំណើរទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយនៅសាលាបឋមសិក្សាទឹកជ្រៅ។*

# ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ



ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមជាធិបតីភាពក្នុងការបើកកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដល់មន្ត្រីក្រសួងអប់រំ។

ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដល់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័រ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ អង្គការ ខេប បានចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដល់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័រ ដែលគាំទ្រហិរញ្ញប្បទានដោយអង្គការយូនីសេហ្វ តាមរយៈ CPDF III ដឹកនាំដោយអង្គការមូលនិធិអាស៊ី។

កម្មវិធីនេះមានគោលបំណងផ្តល់វគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័រ ដោយចាប់ផ្តើមនូវវគ្គមូលដ្ឋានសម្រាប់បុគ្គលិកក្រសួងអប់រំ យុវជន និងកីឡាទាំងអស់ ដែលនឹងបញ្ចប់នៅក្នុងដំណាក់កាលទីពីរ ដោយមានវគ្គបណ្តុះបណ្តាលបន្ថែមលើប្រធានបទជាក់លាក់ ដូចជាការប្រឹក្សាគរុកោសល្យ ការអភិវឌ្ឍលើការសម្រេចចិត្ត និងជំនាញនិយាយជាសាធារណៈ។

កម្មវិធីនេះនឹងចាប់ពីខែមីនា ឆ្នាំ២០២៣នេះតទៅ ដោយចាប់ផ្តើមបណ្តុះបណ្តាលភាពជាអ្នកដឹកនាំមូលដ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់ចំនួន២៥នាក់នៅខេត្តកំពង់ចាម នៅថ្ងៃទី ១៣-១៧ ខែមីនា។ ក្រោមការដឹកនាំកម្មវិធីពីអង្គការមូលនិធិអាស៊ី អង្គការ ខេប បានចូលរួមចំណែកផ្តល់ការអភិវឌ្ឍសម្ភារបណ្តុះបណ្តាល ហើយអង្គការមូលនិធិអាស៊ីនឹងទទួលខុសត្រូវលើការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គោលដៅគម្រោង៖ ២០៧នាក់ (ស្រី៩៥នាក់) ជាបុគ្គលិកក្រសួងអប់រំ រួមទាំងស្ត្រីនៅក្នុងមុខតំណែងជាអ្នកដឹកនាំមកពីមន្ទីរអប់រំខេត្ត) និងឌីជីថលនីយកម្មនៃវគ្គសិក្សាភាពជាអ្នកដឹកនាំនៅលើគេហទំព័រ MoEYS U-learning Platform។ គម្រោងនេះមានគោលបំណងសាកល្បងក្នុងដំណាក់កាលដំបូងរហូតដល់ខែមេសា ឆ្នាំ២០២៣ ហើយបន្ទាប់ពីបញ្ចប់ការរៀបចំសម្ភារបណ្តុះបណ្តាល និងបណ្តុះបណ្តាលបន្ថែមរហូតដល់ខែមិថុនា ឆ្នាំ២០២៣៕

# ការដាក់ឱ្យដំណើរការជាផ្លូវការនៃកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ


លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមជាអធិបតីភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ។

អង្គការ ខេប បានរៀបចំពិធីសម្ពោធស្តីពីការដាក់ឱ្យដំណើរការជាផ្លូវការនៃកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ (Khmer Digital Literacy Programme) ក្រោមអធិបតីភាពលោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នាព្រឹកថ្ងៃទី ២២ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី រាជធានីភ្នំពេញ ដើម្បីលើកកម្ពស់របៀបរៀនថ្មីតាមឌីជីថលនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សានាពេលអនាគត។

កម្មវិធីអក្ខរកម្មឌីជីថលខ្មែរទទួលបានការឧបត្ថម្ភគាំទ្រជំនួយហិរញ្ញប្បទានពីក្រុមហ៊ុន Meta (Facebook) ហើយធ្វើការបង្ហាញអំពីកម្មវិធីសិក្សារបស់ We Think Digital នៅក្នុងប្រទេសកម្ពុជា និងផ្តល់ជាអត្ថប្រយោជន៍ការអនុវត្តកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ ដោយមានវគ្គបណ្តុះបណ្តាលលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៅក្នុងសាលារៀនជំនាន់ថ្មី ជាពិសេសកម្មវិធីនេះបានរួមចំណែកសំខាន់ សូមអានបន្តទំព័រ៤៥...

...តពីទំព័រ៤៤ ដល់ការអប់រំបែបឌីជីថល។

លោកជំទាវ **គឹម សេង្ហានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "**កម្មវិធីអក្ខរកម្មឌីជីថលខ្មែរបានឆ្លើយតបទៅនឹងយុគសម័យឌីជីថលនាពេលបច្ចុប្បន្ន ដោយកម្មវិធីនឹងធ្វើការបង្កើនគុណវឌ្ឍិគ្រូបង្រៀន ក៏ដូចជាសិស្សឱ្យទទួលបាននូវបទពិសោធន៍ និងចំណេះដឹងថ្មីៗលើការប្រើប្រាស់បច្ចេកវិទ្យាមានភាពល្អប្រសើរឡើងនៅក្នុងវិស័យអប់រំ។ ម្យ៉ាងវិញទៀត អក្ខរកម្មឌីជីថល គឺជាបំណិនដែលចាំបាច់សម្រាប់ការសិក្សា ការរស់នៅ និងការបំពេញការងារនៅក្នុងសង្គមនៃសតវត្សរ៍ទី២១ ហើយវាពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងជីវិតប្រចាំថ្ងៃ**"។

កម្មវិធីអក្ខរកម្មឌីជីថលខ្មែរនឹងដាក់ដំណើរការសាកល្បងចំនួន៦ខែ នៅក្នុងសាលារៀនជំនាន់ថ្មីទាំងអស់ នឹងចាប់ផ្តើមអនុវត្តន៍គម្រោងចាប់ពីខែមេសាតទៅ ដោយផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលចំនួន ១២នាក់ ដែលជាគ្រូបង្រៀនផ្នែកបច្ចេកវិទ្យាព័ត៌មាន សម្រាប់ធ្វើការផ្សព្វផ្សាយទៅដល់សិស្សានុសិស្សឱ្យកាន់តែទូលំទូលាយអំពីការប្រើប្រាស់ប្រព័ន្ធឌីជីថលប្រកបដោយភាព



កម្មវិធីអក្ខរកម្មឌីជីថលខ្មែរធ្វើឡើងនៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី រាជធានីភ្នំពេញដោយមានការចូលរួមពី នាយកសាលារៀនជំនាន់ថ្មី និងអង្គការដៃគូ។

# ការឆ្លុះបញ្ចាំងកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន


លោកគ្រូអ្នកគ្រូធ្វើការឆ្លុះបញ្ចាំងពីសកម្មភាពដែលបានចែករំលែកចំណេះដឹងទៅកាន់សិស្សានុសិស្ស។

កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន (ASEAN-DLP)ទទួលបានការគាំទ្រពី Google.org ប្រតិបត្តិដោយអង្គការ ខេប និងសហការជាមួយអង្គការមូលនិធិអាស៊ាន បានរៀបចំពិធីជួបជុំគ្រូបង្គោលស្តីពី **ការឆ្លុះបញ្ចាំងកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន** ដែលធ្វើឡើងនៅសណ្ឋាគារ ពូលូរ៉េ ហូថែល ដើម្បីផ្តល់ឱកាសឱ្យគ្រូបង្គោលទាំងអស់ បានចែករំលែកបញ្ហាប្រឈម និងបទពិសោធន៍ល្អៗ អំឡុងពេលផ្តល់វគ្គបណ្តុះបណ្តាលទៅកាន់អ្នកទទួលផលចុងក្រោយ។

កម្មវិធីនេះ ធ្វើឡើងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៧៦ នាក់ ជាគ្រូបង្គោល មន្ត្រីតំណាងពីខាងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងលើការទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត ព័ត៌មានខុស និងព័ត៌មានក្លែងក្លាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមនៅក្នុងសហគមន៍ និងស្ថានប័នរបស់គ្រូបង្គោល។

លោក **ហ៊ិន ស៊ីមហួន** នាយករងប្រតិបត្តិអង្គការខេបបានមានប្រសាសន៍ថា "**កម្មវិធីអក្ខរកម្មឌីជីថល ដើរតួនាទីយ៉ាងសំខាន់ ដើម្បីការពារខ្លួនពីការបោកបញ្ឆោតនៅលើបណ្តាញសង្គមនាពេលបច្ចុប្បន្ននេះ ហើយវាបានចូលរួមចំណែកផ្សព្វផ្សាយចំណេះដឹងទាក់ទងទៅនឹងការប្រើប្រាស់ឌីជីថលឱ្យកាន់តែទូលំទូលាយប្រកបដោយប្រសិទ្ធិភាព និងលើក** សូមអានបន្តទំព័រ៤៦...

តពីទំព័រ៤៥... ទឹកចិត្តមនុស្សឱ្យក្លាយទៅជាភ្នាក់ងារមួយនៃការផ្លាស់ប្តូរដែលអាចជួយរកឃើញនៃដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិតដែលកើតមានឡើងកៅក្នុងសង្គម”។

លោកស្រី **Cresentia Novianti** ជាអ្នកគ្រប់គ្រងគម្រោងកម្មវិធីអក្ខរកម្មឌីជីថលអាស៊ានបានមានប្រសាសន៍ថា “ពួកយើងជួបគ្នានៅទីនេះ ដើម្បីចែករំលែកបទពិសោធន៍ និងកោតសរសើរដល់គ្រូបង្គោលទាំងអស់ ដែលបានផ្សព្វផ្សាយការយល់ដឹងអំពីអក្ខរកម្មឌីជីថលនៅប្រទេសកម្ពុជា។ សូមអបអរសាទរ! គ្រូបង្គោលទាំងអស់ គឺជាផ្នែកមួយយ៉ាងសំខាន់នៃការកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងទៅនឹងព័ត៌មានមិនពិត និងព័ត៌មានខុសនៅក្នុងប្រទេសរបស់ខ្លួន។ យើងសង្ឃឹមថាជំនាញអក្ខរកម្មឌីជីថលនឹងត្រូវបានពង្រឹង មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែនៅទូទាំងសហគមន៍អាស៊ានទាំងមូល”។

លោកស្រី **Marija Ralic** ជាអ្នកដឹកនាំ Google.org APAC បានមានប្រសាសន៍ថា “យើងមានមោទនភាពក្នុងការគាំទ្រមូលនិធិអាស៊ាន និងអង្គការក្នុងស្រុកដែលមានឈ្មោះថា អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប) ក្នុងការផ្តល់សិទ្ធិអំណាចដល់ប្រជាជនទូទាំងតំបន់នូវជំនាញ



បន្ទាប់ពីធ្វើបទបង្ហាញចប់ គ្រូបង្គោលនឹងទទួលបានកាបូបស្ពាយមួយពីតំណាងមូលនិធិអាស៊ាន។

អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយដ៏មានសារៈសំខាន់ដែលនឹងក្លាយទៅជាគន្លឹះក្នុងការធ្វើឱ្យពួកគេរក្សាការប្រុងប្រយ័ត្ននៅពេលរុករកព័ត៌មានពីពិភពអនឡាញកាន់តែខ្លាំងឡើង។ គ្មានកង្វល់ណាមួយឡើយនៅក្នុងថ្ងៃនេះ វត្តមានគ្រូបង្គោលនឹងដើរតួយ៉ាងសំខាន់នៅក្នុងសហគមន៍របស់ពួកគេយ៉ាងស៊ីជម្រៅ ដើម្បីប្រើប្រាស់បច្ចេកវិទ្យាផ្សេងៗ និងផ្តល់សិទ្ធិអំណាចដល់ខ្លួនឯង ក៏ដូចជាអ្នកដែលនៅជុំវិញពួកគេដើម្បីទប់ស្កាត់ព័ត៌មានមិនពិត។ យើងទន្ទឹងរង់ចាំការបោះជំហានទៅមុខនៃគំនិតផ្តួចផ្តើមនេះនឹងនាំមកនូវការបង្កើតកន្លែងឌីជីថលដែលមានសុវត្ថិភាពជាងមុននៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់អាស៊ាន”។

ការជួបជុំគ្នានេះ សិក្ខាកាមបានចែករំលែកផលសម្រេចបាន បញ្ហាប្រឈម និងរៀបចំផែនការបន្តក្នុងការផ្តល់វគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនេះ ទៅដល់អ្នកទទួលផល។

កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន (ASEAN-DLP) ជាកម្មវិធីកម្រិតតំបន់មួយដែលមានបំណងផ្តល់វគ្គបណ្តុះបណ្តាលស្តីពីអក្ខរកម្មឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយដល់អ្នកទទួលផលយ៉ាងតិចឱ្យបាន ៧០០០នាក់ ទៅដល់យុវជន គ្រូបង្រៀន ឪពុកម្តាយ អាណាព្យាបាលសិស្ស ថ្នាក់ដឹកនាំក្នុងសហគមន៍ និងមន្ត្រីរដ្ឋាភិបាលដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ៕



សិក្ខាកាមចូលរួមសរុបចំនួន ៧៦នាក់ ជាគ្រូបង្គោលកម្មវិធីដែលមានគោលបំណងលើកកម្ពស់ការយល់ដឹងលើការទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត ព័ត៌មានខុស និងព័ត៌មានក្លែងក្លាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមនៅក្នុងសហគមន៍ និងស្ថានប័នរបស់គ្រូបង្គោល។

# អង្គវិបស្សនាបុគ្គលិកប្រចាំឆ្នាំអង្គការ ខេប

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប) បានរៀបចំអង្គវិបស្សនាបុគ្គលិកប្រចាំឆ្នាំ ដែលប្រព្រឹត្តទៅនៅខេត្តព្រះសីហនុ ដែលមានបុគ្គលិកចូលរួមសរុបចំនួន១១៧ នាក់ ស្រី៣៥នាក់។

អង្គវិបស្សនេះ ធ្វើឡើងនៅថ្ងៃទី០៤ ដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ក្នុងគោលបំណង បង្កើតបរិយាកាសរីករាយ និងភាពស្និទ្ធស្នាលរវាងបុគ្គលិកក្នុងគ្រួសារ ខេប ក្រោយពេលបំពេញភារៈកិច្ចរយៈពេលមួយឆ្នាំកន្លងមក និងធ្វើបច្ចុប្បន្នភាពកម្មវិធី និងគោលនយោបាយចាំបាច់របស់ស្ថាប័ន ព្រមទាំងធ្វើបទបង្ហាញស្តីពីផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ (២០២០-២០២៥) ការធ្វើបច្ចុប្បន្នភាពគោលនយោបាយយេនឌ័ររបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងរបស់គណៈកម្មការមូលនិធិសុខភាពបុគ្គលិក ក៏ដូចជាធ្វើការឆ្លុះបញ្ចាំងពីការអនុវត្តគម្រោងនាពេលបច្ចុប្បន្ន។

លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) បានមានប្រសាសន៍ថា "ខេប អាចជាអង្គការក្នុងស្រុកតែមួយគត់ ដែលទទួលបានហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡា និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ ក្រោយពីការខកខានការប្រជុំអស់រយៈពេល៣ឆ្នាំ ដោយសារបញ្ហាការរីករាលដាលវីរុសកូវីដ-១៩ ដែលបានប៉ះពាល់ដល់ការប្រតិបត្តិគម្រោងនានាយ៉ាងណាក៏ដោយ ប៉ុន្តែខេបនៅតែទទួលបានផលវិជ្ជមានទាក់ទងនឹងផ្នែកអាយស៊ីធី( ICT)និង ឌីជីថល (Digital) ដែលធ្វើឱ្យខេបអាចបន្តធ្វើការបានគ្រប់កាលៈទេសៈ នេះជាករណីសិក្សាថ្មីមួយដែលខេបអាចទទួលគម្រោងថ្មីៗទាក់ទងនឹងផ្នែកICT ។ លោកបានបន្តទៀតថា ក្នុងឆ្នាំ២០២២ កន្លងទៅ ខេបមានគម្រោងចំនួន២៣ និងមានគម្រោងចំនួន ៦ ត្រូវបានបញ្ចប់ក្នុងឆ្នាំតែមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ខេបនៅតែបន្តអភិវឌ្ឍកម្មវិធីថ្មីៗប្រកបដោយជោគជ័យ ដែលឈានទៅអនុម័តគម្រោងថ្មីៗចំនួនប្រាំ ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំដដែលនេះ និងសូមឱ្យបុគ្គលិកទាំងអស់យកចិត្តទុកដាក់ក្នុងការបន្តកិច្ចការរបស់ខេប ឱ្យទទួលបានសមិទ្ធផលល្អ និងទទួលបានគម្រោងថ្មីៗបន្ថែមទៀត"។

លោក ហ៊ាង កុយ ប្រធានក្រុមប្រឹក្សាភិបាលបានលើកឡើងថា "ទោះបីស្ថិតក្នុងស្ថានភាពលំបាក ដោយសារវីរុសកូវីដ-១៩យ៉ាងណាក៏ដោយ ខេបបានសម្របខ្លួនចូលក្នុងបរិបទថ្មីនេះយ៉ាងឆាប់រហ័ស និងបានស្វះស្វែងរកវិធីសាស្ត្រថ្មីៗ ដើម្បីជួយអន្តរាគមន៍ដល់សាលារៀនគោលដៅរបស់ខ្លួន ហើយជាលទ្ធផល ខេបនៅតែទទួលបានផលវិជ្ជមានក្នុងការអនុវត្តគម្រោង។ នេះសបញ្ជាក់ឱ្យឃើញថា ខេប ពិតជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់វិស័យអប់រំ"។

អំឡុងពេលអង្គវិបស្សនា អ្នកគ្រប់គ្រងជាន់ខ្ពស់ និងថ្នាក់ដឹកនាំសំខាន់ៗក្នុងអង្គការខេប បានធ្វើបទបង្ហាញស្តីពីផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ ឆ្នាំ, គោលនយោបាយយេនឌ័រ, សាលារៀនជំនាន់ថ្មី និងធ្វើបច្ចុប្បន្នភាពរបស់គម្រោងនីមួយៗ ក៏ដូចជាតាមផ្នែកហិរញ្ញវត្ថុ ផ្នែករដ្ឋបាល និងផ្នែកICT ។

បូកសរុបលទ្ធផល អង្គវិបស្សនាប្រចាំឆ្នាំ បានផ្តោតលើផែនការយុទ្ធសាស្ត្រថ្មី២០២០-២០២២ ទាំង៩របស់ខេបរួមមាន៖ ១) ការអប់រំថ្នាក់អនឡាញ (Online learning)។ ២)គំរូអប់រំបែបសតវត្សទី២១ដែលផ្តោតលើ STEM, ICT។ ៣)ការបំប៉នបន្ថែមសិស្សរៀនយឺតនិងថ្នាក់ពន្លឿន។ ៤)ការផ្តល់ប្រឹក្សាជូនគ្រូបង្រៀនដោយផ្តល់នូវគំរូចម្រុះដូចជាសាលាជំនាន់ថ្មី សាលាធនធានមានមួយគម្រូ និងវិទ្យាស្ថានបាត់ដំបង។ ៥)ការអប់រំបំណិនជីវិត និងជំនាញការងារ។ ៦)ការផ្សព្វផ្សាយយុវជន។ ៧)កម្មវិធីមត្តេយ្យសិក្សាដោយផ្តោតលើតំណភ្ជាប់ជាមួយ NGS។ ៨) ការអប់រំប្រជាពលរដ្ឋសកល និងចុងក្រោយការពង្រីក NGS៕



អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជាដែលចាប់ផ្តើមអនុវត្តគម្រោងតាំងពីខែមេសា ឆ្នាំ១៩៨៦ ហេតុមកបច្ចុប្បន្នមានបុគ្គលិកច្រើនជាង១០០នាក់ និងកំពុងអនុវត្តសកម្មភាពគម្រោងក្នុងរាជធានីខេត្តចំនួន១៤។